# កម្ពុជា (ចំណាត់ថ្នាក់ក្រុមទី៣)

រដ្ឋាភិបាលកម្ពុជាមិនបានបំពេញឱ្យបានពេញលេញតាមស្តង់ដារអប្បរមាសម្រាប់ការលុបបំបាត់អំពើជួញដូរមនុស្ស និងមិនបានខិតខំប្រឹងប្រែងខ្លាំងក្លានោះទេ ពាក់ព័ន្ធនឹងសមត្ថភាពរបស់ខ្លួនក្នុងការប្រឆាំងអំពើជួញដូរមនុស្ស (បើទោះបីជាយើងពិចារណាពីផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩ ក៏ដោយ) ដូច្នេះកម្ពុជានៅតែស្ថិតក្នុងចំណាត់ក្រុមទី ៣ ។ ទោះបីជាមានភាពខ្វះចន្លោះក្នុងកិច្ចខិតខំប្រឹងប្រែងសំខាន់ៗក៏ដោយ ក៏រដ្ឋាភិបាលបានចាត់វិធានការមួយចំនួនដើម្បីឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស រួមមានទាំងការស៊ើបអង្កេត ការជំនុំជម្រះ និងកាត់ទោសជនល្មើសជួញដូរមនុស្សបានកាន់តែច្រើន ការបង្កើតក្រុមការងារពិសេសមួយដើម្បីស៊ើបអង្កេតរបាយការណ៍ដែលអាចជឿទុកចិត្តបាននៃប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតទ្រង់ទ្រាយធំដែលពាក់ព័ន្ធនឹងសូចនាករនៃពលកម្មដោយបង្ខំ និងការកំណត់អត្តសញ្ញាណនិងផ្តល់សេវា ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅកម្ពុជាបន្ថែមទៀត។ ទោះជាយ៉ាងណាក៏ដោយ អំពើពុករលួយ និងការឃុបឃិតរបស់មន្ត្រីក្នុងឧក្រិដ្ឋកម្មជួញដូរ រួមទាំងការឃុបឃិតដែលធ្វើឡើងដោយឧត្តមមន្ត្រីដែលមានឋានៈខ្ពស់ៗ នៅតែមានលក្ខណៈទូលំទូលាយ និងរីករាលដាល ដែលបណ្តាលឱ្យការពង្រឹងការអនុវត្តច្បាប់កើតមានដោយកន្លែង និងកើតឡើងដោយផ្អែកលើហេតុផលនយោបាយ ហើយបានរារាំងដល់សកម្មភាពអនុវត្តច្បាប់ក្នុងឆ្នាំកន្លងមកនេះ។ អាជ្ញាធរមិនបានស៊ើបអង្កេត ឬចាត់វិធានការព្រហ្មទណ្ឌចំពោះមន្ត្រីដែលជាប់ពាក់ព័ន្ធ ដូចមានក្នុងរបាយការណ៍ដ៏ទូលំទូលាយ និងគួរឱ្យជឿជាក់បានជាពិសេសជាមួយម្ចាស់អាជីវកម្មគ្មានគុណធម៌ ដែលបានធ្វើឱ្យមនុស្សប្រុស ស្រី និងកុមារ រាប់ពាន់នាក់នៅទូទាំងប្រទេសធ្លាក់ខ្លួនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតាមប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត កន្លែងសេវាកម្សាន្ត និង នៅតាមទូកនេសាទ។ កិច្ចអនុវត្តច្បាប់មិនបានដោះស្រាយដោយប្រសិទ្ធភាព នូវបញ្ហាការងារដោយបង្ខំនៅក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតនោះទេ។ រដ្ឋាភិបាលបានបរាជ័យជាបន្តបន្ទាប់ក្នុងការត្រួតពិនិត្យ ឬផ្តល់យុត្តិធម៌ក្នុងឧក្រិដ្ឋកម្មជួញដូរមនុស្សប្រកបដោយសមធម៌ សម្រាប់ពលករបរទេសដែលត្រូវបានសង្គ្រោះចេញពីប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត។ រដ្ឋាភិបាលមិនបានត្រួតពិនិត្យពួកគេជាមុន ពាក់ព័ន្ធនឹងសូចនាករនៃការជួញដូរមនុស្សនោះទេ។ ជាលទ្ធផល អាជ្ញាធរមិនបានផ្តល់ ឬបញ្ជូនជនបរទេស ដែលអាចជាជនរងគ្រោះ នៃប្រតិបត្តិការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណេតទៅទទួលសេវាកម្មនោះទេ ដោយថែមទាំងដាក់ពិន័យមិនសមរម្យដល់ពួកគេ ដោយសារឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្ត ដែលនោះជាលទ្ធផលផ្ទាល់កើតឡើងដោយសារពួកគេត្រូវបានជួញដូរ រួមទាំងមានការឃុំឃាំងជនរងគ្រោះទាំងនោះដោយមិនកំណត់ពេលវេលា គឺរហូតទាល់តែពួកគេ

បង់ប្រាក់សំណូកដល់ប៉ូលីសដើម្បីដោះលែង ឬរហូតទាល់តែស្ថានទូតបរទេសរបស់ពួកគេផ្តល់មូលនិធិដល់ពួកគេដើម្បីចាកចេញពីកម្ពុជា។

## អនុសាសន៍អាទិភាព៖

1. ស៊ើបអង្កេត និងផ្តន្ទាទោសជនល្មើសជួញដូរ រួមទាំងមន្ត្រីឃុបឃិត ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មពលកម្មដោយបង្ខំក្នុងប្រតិបត្តិការឆបោកតាមប្រព័ន្ធអ៊ិនធឺណិត (cyber scam operations)។
2. អនុវត្តឱ្យបានពេញលេញ គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអនុវត្តជាមួយជនសង្ស័យរងគ្រោះជាជនជាតិខ្មែរ និងជនបរទេស និងបណ្តុះបណ្តាលមន្ត្រី ទូទាំងប្រទេស ពីរបៀបអនុវត្តគោលការណ៍ណែនាំនោះ។
3. ត្រួតពិនិត្យបុគ្គលទាំងអស់ដែលកំពុងជាប់ក្នុងមណ្ឌលឃុំឃាំង ឬឃុំខ្លួនអន្តោប្រវេសន៍ ដើម្បីស្វែងរកសូចនាករពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស រួមបញ្ចូលទាំងកម្មករ បុរស ក្មេងប្រុស បុគ្គល LGBTQI+ និងជនដែលមានពិការភាព។
4. ស៊ើបអង្កេត កាត់ទោសបទល្មើសជួញដូរមនុស្ស និងដាក់ទោសទណ្ឌឱ្យបានគ្រប់គ្រាន់ លើជនល្មើស ដោយគួរឱ្យមានទោសជាប់ពន្ធនាគារធ្ងន់ធ្ងរស្របតាមច្បាប់។
5. បង្កើនថវិកាដល់អង្គភាពអនុវត្តច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស និងផ្តល់ថវិកាជាមុនក្នុងការស៊ើបអង្កេតជាជាងផ្តល់តាមពេលក្រោយក្នុងលក្ខណៈសំណង។
6. ចាត់ចែងធនធានបន្ថែមដល់នគរបាលប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីសម្រួលដល់ការឃ្លាំមើលជនជាប់ចោទដែលត្រូវបានដោះលែងក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលរង់ចាំការជំនុំជម្រះ។
7. បង្កើន ឬចាប់ផ្តើម ការចុះធ្វើអធិការកិច្ចការងារដោយមិនប្រកាសប្រាប់មុន ក្នុងវិស័យការងារដែលអាចឱ្យងាយមានជនរងគ្រោះ ជាពិសេសការងារនៅតាមតំបន់សេដ្ឋកិច្ចពិសេស និងនៅតាមឡជដ្ឋ កន្លែងផ្តល់សេវាកម្សាន្ត ការដ្ឋានសំណង់ និងចម្ការ ដោយផ្តោតលើការពិនិត្យលើសញ្ញាណ ការជួញដូរកម្លាំងពលកម្ម ការធ្វើការងារដើម្បីដោះបំណុល និងការទទួលខុសត្រូវរបស់ម្ចាស់អាជីវកម្មចំពោះមុខច្បាប់។
8. បង្កើនការផ្តល់សេវាសម្រាប់ជនរងគ្រោះជាមនុស្សប្រុស ជាពិសេសបុរស និងកុមារាដែលត្រូវបានកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងអាជីវកម្មនេសាទនៅក្រៅប្រទេស។
9. ឧបត្ថម្ភលើកទឹកចិត្ត ដល់ការចូលរួមរបស់ជនរងគ្រោះក្នុងនិងក្រៅស្រុក ក្នុងនីតិវិធីព្រហ្មទណ្ឌនិងរដ្ឋប្បវេណី រួមទាំងការបង្កើតមូលនិធិជនរងគ្រោះ និងផ្តល់ការអនុញ្ញាតឱ្យធ្វើការងារ ផ្តល់ជម្រកស្នាក់នៅបណ្តោះអាសន្ន ឬស្ថានភាពអន្តោប្រវេសន៍ពាក់ព័ន្ធដទៃទៀតដល់ជនរងគ្រោះបរទេសដែលមានបំណងចង់ស្នាក់នៅក្នុងប្រទេសក្នុងអំឡុងពេលដំណើរការនីតិវិធី។
10. អនុវត្តប្រព័ន្ធត្រួតពិនិត្យតាមដាន ប្រមូល និងរាយការណ៍ទិន្នន័យអំពីការផ្តន្ទាទោសប្រឆាំងអំពើជួញដូរមនុស្សនិងកិច្ចខិតខំប្រឹងប្រែងការពារជនរងគ្រោះ ព្រមទាំងផ្សព្វផ្សាយទិន្នន័យក្នុងចំណោមស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធដោយការពារអត្តសញ្ញាណ និងឯកជនភាពរបស់ជនរងគ្រោះ។

11. លុបបំបាត់ការយកថ្លៃឈ្នួលដែលត្រូវបង់ដោយពលករ ក្នុងការជ្រើសរើសពលករ រឺថ្លៃឈ្នួលក្នុងការដាក់បញ្ចូលពលករឱ្យធ្វើការ ដែលពលករត្រូវបង់ទៅភ្នាក់ងារជ្រើសរើសពលករកម្ពុជា និងធានាថាថ្លៃឈ្នួលទាំងនោះនឹងត្រូវបង់ដោយថៅកែនយោជក ជំនួសវិញ ។
12. បង្កើនការធ្វើអធិការកិច្ច និងការត្រួតពិនិត្យស្ថាប័នផ្តល់ប្រាក់កម្ចី រួមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុឯកជនដើម្បីកាត់បន្ថយភាពងាយរងគ្រោះដោយសារការបង្ខិតបង្ខំឱ្យធ្វើការដោះបំណុល ក្នុងចំណោមសហគមន៍ដែលជួបបញ្ហាលំបាកផ្នែកសេដ្ឋកិច្ច។
13. អនុញ្ញាតឱ្យមានការសងប្រាក់នៅពេលមានការផ្តន្ទាទោសជនជួញដូរ និងបង្កើតព្រមទាំងបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធលើនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ការគណនា និងការផ្តល់សំណង។
14. បង្កើតនិងបែងចែកធនធានដើម្បីអនុវត្តនីតិវិធីជាប្រព័ន្ធនៅតាមបេសសកម្មការទូតនានា ដើម្បីជួយជនរងគ្រោះកម្ពុជានៅបរទេស រួមទាំងនៅក្នុងប្រទេសទាំងឡាយណាដែលគ្មានតំណាងការទូតកម្ពុជា។
15. កែប្រែបទប្បញ្ញត្តិពាក់ព័ន្ធនានាស្តីពីការផ្តល់សិទ្ធិជ្រើសរើសពលករ និងតម្រូវការក្នុងកិច្ចសន្យា ដើម្បីរួមបញ្ចូលភាសាដែលពង្រឹងលើការការពារកម្មករ និងសិទ្ធិការងារ។
16. ពង្រឹងកិច្ចខិតខំប្រឹងប្រែងធ្វើអធិការកិច្ចទីភ្នាក់ងារជ្រើសរើសពលករឯកជន និងសាខាឬភ្នាក់ងារក្រោមកិច្ចសន្យារបស់ពួកគេ ដោយកំណត់សញ្ញាណការជ្រើសរើសបែបក្លែងបន្លំ និងសូចនាករជួញដូរមនុស្សផ្សេងៗ។
17. ដាក់បញ្ចូលមតិយោបល់របស់អង្គការមិនមែនរដ្ឋាភិបាលទៅក្នុងគោលនយោបាយជាផ្លូវការស្តីពីការផ្ទេរអំណាចមេបាកុមារដែលជាជនរងគ្រោះ។

# ការជំនុំជម្រះ

រដ្ឋាភិបាលបានបន្ត កិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ដែលមានលក្ខណៈចម្រុះ។ ការឃុបឃិតរបស់មន្ត្រីនៅតែជាកង្វល់ដ៏ចម្បងមួយ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ បានកំណត់ការជួញដូរផ្លូវភេទ និងការជួញដូរកម្លាំងពលកម្ម ថាជាបទឧក្រិដ្ឋ ដែលមានការផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំសម្រាប់បទល្មើសពាក់ព័ន្ធនឹងជនរងគ្រោះជានីតិជន និងដាក់ពន្ធនាគារពី ១៥ ទៅ ២០ឆ្នាំ ដល់ជនល្មើសពាក់ព័ន្ធនឹងជនរងគ្រោះជាកុមារ ។ ទោសទណ្ឌទាំងនេះមានភាពតឹងរ៉ឹងគ្រប់គ្រាន់ ទាក់ទងទៅនឹងការជួញដូរផ្លូវភេទ សមស្របទៅនឹងបទឧក្រិដ្ឋធ្ងន់ធ្ងរផ្សេងទៀត ដូចជាការរំលោភសេពសន្ថវៈជាដើម។ អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថា នៅក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាលមិនបានចេញការពិន័យព្រហ្មទណ្ឌក្រោមច្បាប់ប្រឆាំងការជួញដូរ ចំពោះជនល្មើសជួញដូរដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្មនោះទេ។ ផ្ទុយទៅវិញ រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ការងារដើម្បីចេញការផាកពិន័យ និង/ឬទោសដាក់ពន្ធនាគាររយៈពេលខ្លី ដែលមានចាប់ពី៦

ថ្ងៃ ទៅ ១ខែ ដែលការណ៍នេះមិនអាចតំណាងឱ្យការផ្តន្ទាទោសដែលមានលក្ខណៈគ្រប់គ្រាន់ ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មនាពេលអនាគត ឬផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនោះទេ។ រដ្ឋាភិបាលមិនបានរក្សាកំណត់ត្រាគោល ឬមូលដ្ឋានទិន្នន័យ នៃការស៊ើបអង្កេត និងដំណើរការនីតិវិធីតុលាការឡើយ។ ដូច្នេះទិន្នន័យរួមនៃការអនុវត្តច្បាប់គឺមិនមានលក្ខណៈពេញលេញទេ។ ឆ្នាំនេះជាឆ្នាំទីពីរហើយ ដែលប៉ូលិសមិនបានរាយការណ៍អំពីទិន្នន័យគ្រប់ជ្រុងជ្រោយស្តីពីការស៊ើបអង្កេតដែលខ្លួនបានធ្វើ ប្រឆាំងការជួញដូរមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ ជាផ្នែកនៃប្រតិបត្តិការប៉ូលីសរយៈពេលបីខែ ដើម្បីស៊ើបអង្កេតរបាយការណ៍នៃករណីជួញដូរមនុស្សនៅទូទាំងប្រទេស ប៉ូលីសបានរាយការណ៍ថាបានស៊ើបអង្កេតករណីចំនួន ៦០០ ករណី ។ អាជ្ញាធរមិនបានផ្តល់ព័ត៌មានលម្អិតអំពីការស៊ើបអង្កេត ឬការជំនុំជម្រះករណីជួញដូរមនុស្សណាមួយដែលជាលទ្ធផលកើតចេញពីការស៊ើបអង្កេតទាំងនោះទេ។ នៅក្នុងឆ្នាំ ២០២២ មន្ត្រីក្រសួងយុត្តិធម៌ បានប្រមូលទិន្នន័យការជំនុំជម្រះក្តី និងការផ្តន្ទាទោស ដោយដៃ ពីតុលាការនៅតាមស្រុកនីមួយៗ នៅទូទាំងប្រទេស។ ទោះជាយ៉ាងណាក៏ដោយ ដូចនៅក្នុងអំឡុងពេលនៃរបាយការណ៍មុន អាជ្ញាធរតុលាការប្រហែលបានរាប់បញ្ចូលករណីរំលោភសេពសន្ថវៈ និងឧក្រិដ្ឋកម្មផ្សេងទៀតដែលស្ថិតនៅក្រៅនិយមន័យ (អនុលោមតាមស្តង់ដារអន្តរជាតិ) នៃអំពើជួញដូរមនុស្ស ទៅក្នុងទិន្នន័យដែលបានរាយការណ៍របស់ពួកគេ។ ដូច្នេះ ចំនួនពិតនៃការជំនុំជម្រះករណីជួញដូរមនុស្ស និងការផ្តន្ទាទោសទំនងជាទាបជាងតួលេខដែលមានក្នុងរបាយការណ៍។ ក្នុងឆ្នាំ ២០២២ រដ្ឋាភិបាលបានជំនុំជម្រះជនសង្ស័យក្នុងករណីជួញដូរមនុស្សចំនួន ២៩២ នាក់ដែលជាប់ពាក់ព័ន្ធក្នុង ៨៨ ករណី ក្រោមច្បាប់ប្រឆាំងការជួញដូរ។ នៅក្នុងនោះមាន ១៦ ករណីពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទ ២៤ករណីពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និង៤៧ករណីពាក់ព័ន្ធនឹងទម្រង់នៃការជួញដូរដែលមិនបានបញ្ជាក់ឱ្យច្បាស់។ បើប្រៀបធៀបនឹងតួលេខក្នុងឆ្នាំ២០២១ មានករណីសរុបចំនួន ៦៤ករណី ដែលត្រូវបានជំនុំជម្រះក្រោមច្បាប់ប្រឆាំងការជួញដូរ។ នៅក្នុងនោះមាន ៤ករណីពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទ ៣៧ករណីពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និង ២៣ករណីពាក់ព័ន្ធនឹងទម្រង់នៃការជួញដូរដែលមិនបានបញ្ជាក់ឱ្យច្បាស់។ រដ្ឋាភិបាលបានរាយការណ៍ថាខ្លួនបានកាត់ទោសជនល្មើសជួញដូរមនុស្សចំនួន ១៧៤ នាក់ ក្នុងនោះមាន ១៣នាក់ពីបទជួញដូរផ្លូវភេទ និង ៤២នាក់ក្នុងករណីពលកម្មដោយបង្ខំ។ បើប្រៀបធៀបនឹងឆ្នាំ២០២១ ជនល្មើសជួញដូរមនុស្សចំនួន ៣៨នាក់ត្រូវបានកាត់ទោស ក្នុងនោះមាន ១នាក់ក្នុងករណីជួញដូរផ្លូវភេទ និង៣៥នាក់ក្នុងករណីពលកម្មដោយបង្ខំ។ អ្នកសង្កេតការណ៍បានរាយការណ៍ថាយ៉ាងហោចណាស់មានការកាត់ទោសបុគ្គល៣រូបដែលមិនមែនជាជនល្មើសជួញដូរមនុស្សទេ ប៉ុន្តែផ្ទុយទៅវិញគឺជាជនរងគ្រោះផ្នែកតស៊ូមតិដែលបានទទួលទោសទណ្ឌដោយសារពួកគេប៉ុនប៉ងរំដោះជនរងគ្រោះពីប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត។ ក្នុងករណីខ្លះ តុលាការបានផ្តល់សាលក្រមដោយផ្ទាល់មាត់ ហើយដោយមិនធ្វើកំណត់ត្រាជាផ្លូវការនោះទេ។ តុលាការក៏ប្រហែលជាបានកាត់ទោសកំបាំងមុខជនល្មើសជួញដូរមនុស្ស ដែលបានគេចពីការចាប់ខ្លួនផងដែរ។

ច្បាប់បានអនុញ្ញាតឱ្យមានការកាត់ទោសឡើងវិញ ចំពោះជនសង្ស័យដែលបានគេចពីការចាប់ខ្លួន និងត្រូវបានកាត់ទោសដោយកំបាំងមុខ ហើយអ្នកសង្កេតការណ៍បានរាយការណ៍ថា តុលាការជាញឹកញាប់បានដោះលែងជនល្មើសជួញដូរមនុស្សដែលត្រូវបានកាត់ទោសកំបាំងមុខ នៅពេលមានការកាត់ទោសឡើងវិញ ដោយសារតែអំពើពុករលួយ និងការឃុបឃិតរបស់មន្ត្រី។

នៅទូទាំងប្រទេស ជារឿយៗអាជ្ញាធរអនុវត្តច្បាប់មិនបានស៊ើបអង្កេត ឬកាត់ទោសជនសង្ស័យ ឬផ្តន្ទាទោសជនល្មើសជួញដូរមនុស្សនោះទេ បើទោះបីជាមានការចោទប្រកាន់ដែលគួរឱ្យទុកចិត្តបានក៏ដោយ ដោយសារឧបសគ្គផ្នែកធនធាន និងការឃុបឃិតរបស់មន្ត្រី។ ចុងចោទមួយចំនួនបានរត់គេចខ្លួនមុនថ្ងៃកាត់ក្តីរបស់ពួកគេ ដោយសារប៉ូលីសយុត្តិធម៌ខ្វះធនធានក្នុងការត្រួតពិនិត្យតាមដានពួកគេ ក្នុងខណៈពេលដែលពួកគេត្រូវបានដោះលែងនៅឋិតក្រោម "ការត្រួតពិនិត្យរបស់តុលាការ" រង់ចាំការកាត់ក្តី។ តុលាការបានកាត់ទោសជនល្មើសជួញដូរ ដោយកំបាំងមុខ។ អាជ្ញាធរកម្រចេញដីកាចាប់ខ្លួនចុងចោទដែលបានរត់គេចខ្លួន លើកលែងតែក្នុងករណីដែលមានអង្គការក្រៅរដ្ឋាភិបាលជួយតាមដាន និងចាប់ខ្លួនពួកគេប៉ុណ្ណោះ។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនមានចែងពីគោលការណ៍ណែនាំ បទប្បញ្ញត្តិក្នុងការពិនិត្យតាមដាន ឬមានចែងជាកថាខណ្ឌដែលមានភាសាបង្ហាញពីកាតព្វកិច្ចអនុវត្តច្បាប់ជាក់លាក់ទាក់ទងនឹងការត្រួតពិនិត្យតាមដានរបស់តុលាការនោះទេ។ ដោយលើកឡើងពីឧបសគ្គផ្នែកធនធាន ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត មិនបានជំរុញពន្លឿនសំណុំរឿងក្តីជួញដូរមនុស្សទាំងអស់ ដែលប៉ូលិសបានផ្តល់ភស្តុតាងនោះទេ។ អ្នកជំនាញក្នុងស្រុកបានបន្តរាយការណ៍ថា ករណីពាក់ព័ន្ធជនបរទេសទំនងជានាំឱ្យមានការផ្តន្ទាទោសលើការជួញដូរមនុស្ស ជាងករណីពាក់ព័ន្ធនឹងជនសង្ស័យកម្ពុជា ដែលជារឿយៗមន្ត្រីបានកាត់បន្ថយការចោទប្រកាន់មកជាបទល្មើសមិនសូវធ្ងន់ធ្ងរទៅវិញ។ រដ្ឋាភិបាលបានបង្កើនប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅតាមខេត្តនានានៅក្រៅពីរាជធានី ប៉ុន្តែសហគមន៍ជនបទ ដាច់ស្រយាល មិនបានទទួលអត្ថប្រយោជន៍ពីការអនុវត្តច្បាប់ប្រកបដោយសមធម៌ទេ ដោយសារតែការឃុបឃិតរបស់មន្ត្រី និងដោយសារអំពើពុករលួយ ការអនុវត្តច្បាប់នៅក្នុងតំបន់ទាំងនេះមិនបានកាត់ទោសជនល្មើសជួញដូរដែលត្រូវបានចោទប្រកាន់ ដែលមានបណ្តាញទំនាក់ទំនងជាមួយមន្ត្រីរដ្ឋាភិបាលនោះទេ។

រដ្ឋាភិបាលមិនបានស៊ើបអង្កេត កាត់ទោស ឬផ្តន្ទាទោសមន្ត្រីរដ្ឋាភិបាលឃុបឃិតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជួញដូរមនុស្សនោះទេ។ អំពើពុករលួយ និងការឃុបឃិតរបស់មន្ត្រីក្នុងឧក្រិដ្ឋកម្មជួញដូរមនុស្សនៅតាមកម្រិតជាច្រើនក្នុងជួររដ្ឋាភិបាល នៅតែជាកង្វល់ដ៏ចម្បង ដែលរារាំងដល់សកម្មភាពអនុវត្តច្បាប់ និងបន្តនាំឱ្យមាននិទណ្ឌភាពក្នុងអំឡុងឆ្នាំកន្លងមក។ អ្នកសង្កេតការណ៍បានរាយការណ៍ថា អាជ្ញាធរមូលដ្ឋាន មន្ត្រីអនុវត្តច្បាប់ និងកងកម្លាំងសន្តិសុខបានសម្របសម្រួលដោយផ្ទាល់នូវឧក្រិដ្ឋកម្មជួញដូរមនុស្សដោយចូលរួមឃុបឃិតជាមួយបណ្តាញ

ឧក្រិដ្ឋកម្ម។ អង្គការមិនមែនរដ្ឋាភិបាលបានបន្តរាយការណ៍ពីករណីដែល ជនរងគ្រោះដោយការជួញដូរបានចោទមន្ត្រីកម្ពុជាថាបានឃុបឃិតជាមួយមេខ្យល់ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មជួញដូរមនុស្ស។ អង្គការក្រៅរដ្ឋាភិបាលក៏បានបន្តចោទប្រកាន់ប៉ូលិស និងមន្ត្រីដទៃទៀតថាបានឃុបឃិតក្នុងប្រតិបត្តិការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិតដែលបានបង្ខំប្រជាជនរាប់ពាន់នាក់មកពី សាធារណរដ្ឋប្រជាមានិតចិន អាស៊ីអាគ្នេយ៍ និងជនបរទេសផ្សេងទៀតឱ្យធ្វើការនៅក្នុង "មជ្ឈមណ្ឌលហៅទូរស័ព្ទ" នៅក្នុងខេត្តព្រះសីហនុ និងតាមទីតាំងផ្សេងៗទៀត។ អ្នកសង្កេតការណ៍បានចោទប្រកាន់ថា ព្រះរាជអាជ្ញា និងចៅក្រមបានទទួលយកសំណូកជាថ្នូរនឹងការទម្លាក់ចោលការចោទប្រកាន់ ការលើកលែងទោស និងកាត់បន្ថយការផ្តន្ទាទោស។ មន្ត្រីពុករលួយជារឿយៗរារាំងវឌ្ឍនភាពក្នុងករណីដែលជនល្មើសត្រូវបានចោទប្រកាន់ មានទំនាក់ទំនងផ្នែកនយោបាយ ឧក្រិដ្ឋកម្ម ឬផ្នែកសេដ្ឋកិច្ច ជាមួយមន្ត្រីរដ្ឋាភិបាល។ ប្រតិបត្តិការបង្ក្រាបរបស់សមត្ថកិច្ចលើគ្រឹះស្ថានដែលអាជ្ញាធរជឿថាការជួញដូរផ្លូវភេទបានកើតឡើងជួនកាលមិនបានជោគជ័យនោះទេដោយសារមានការឱ្យដំណឹងជាមុនពីប៉ូលិសនៅតាមមូលដ្ឋានទាំងនោះ។ ប៉ូលីសមួយចំនួនត្រូវបានគេរាយការណ៍ថាបានការពារគ្រឹះស្ថានទាំងនោះ ជាថ្នូរនឹងការទទួលបានការបង់ប្រាក់ប្រចាំខែពីម្ចាស់អាជីវកម្ម ឬទទួលបានការរួមភេទជាមួយជនរងគ្រោះ។ ជារឿយៗអាជ្ញាធរបានមើលរំលង បដិសេធ ឬចាត់ទុកថាមិនសំខាន់ ចំពោះការរំលោភបំពានផ្នែកការងារ រួមទាំងពលកម្មកុមារដោយបង្ខំនៅក្នុងរោងចក្រ និងនៅតាមឡឥដ្ឋ ហើយបានឃុបឃិតជាមួយម្ចាស់សិប្បកម្មផលិតឥដ្ឋដើម្បីចាប់ខ្លួន ដាក់គុក និងបញ្ជូនកម្មករដែលជាប់កិច្ចសន្យាដែលបានព្យាយាមរត់គេចខ្លួន ឱ្យត្រឡប់មកវិញ។ អ្នកសង្កេតការណ៍បានរាយការណ៍ថា មន្ត្រីគយ និងមន្ត្រីអន្តោប្រវេសន៍បានទទួលយកសំណូកពីជនល្មើសជួញដូរមនុស្ស ដើម្បីជួយសម្រួលឱ្យជនរងគ្រោះបានចូលមកប្រទេសកម្ពុជា បន្ទាប់មកជនល្មើសជួញដូរមនុស្សទាំងនោះ បានកេងប្រវ័ញ្ចជនរងគ្រោះ នៅក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត។

រដ្ឋាភិបាលបានរាយការណ៍ថា ក្រសួងយុត្តិធម៌ បានបង្កើតក្រុមការងារពិសេសមួយ ដើម្បីតាមដាន និងស៊ើបអង្កេត ការរាយការណ៍ពីប្រតិបត្តិការជួញដូរមនុស្សទ្រង់ទ្រាយធំនៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់ រួមមាននៅក្នុងខេត្តព្រះសីហនុ បន្ទាយមានជ័យ ឧត្តរមានជ័យ ស្វាយរៀង តាកែវ និងខេត្តកណ្តាល។ ក្រុមមន្ត្រីបានរាយការណ៍ពីការស៊ើបអង្កេតករណីចំនួន ៦០០ករណី ថាជាផ្នែកមួយនៃប្រតិបត្តិការរយៈពេល ៣ខែ ដែលចាប់ផ្តើមនៅខែសីហា ឆ្នាំ២០២២ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានផ្តល់ព័ត៌មានលម្អិតបន្ថែមលើករណីទាំងនោះឡើយ។ អ្នកសង្កេតការណ៍បានរាយការណ៍ថាមន្ត្រីរដ្ឋាភិបាលដែលដឹងព័ត៌មានអំពីប្រតិបត្តិការរបស់ប៉ូលីសបានជូនដំណឹងជាមុនដល់ប្រតិបត្តិករបោកប្រាស់តាមអ៊ីនធឺណិតមុនពេលមានការចូលបង្ក្រាបរបស់ប៉ូលីស។ អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថា មន្ត្រីជាន់ខ្ពស់បានយាយី និងបំភិតបំភ័យអ្នកតស៊ូមតិប្រឆាំងអំពើជួញដូរ

មនុស្ស ដែលបានពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មដោយបង្ខំនៅក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត។

រដ្ឋាភិបាលបានរាយការណ៍ថា ខ្លួនបានសហការជាមួយរដ្ឋាភិបាលនៃប្រទេសចិន ថៃ សហរដ្ឋអាមេរិក និងវៀតណាម លើការស៊ើបអង្កេតករណីជួញដូរមនុស្ស ប៉ុន្តែរដ្ឋាភិបាលមិនបានរាយការណ៍ពីកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ជាមួយរដ្ឋាភិបាលបរទេសលើការស៊ើបអង្កេតករណីជួញដូរមនុស្សក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតនោះទេ។ រដ្ឋាភិបាលក៏បានបន្តផងដែរនូវកិច្ចព្រមព្រៀងទ្វេភាគីផ្លូវការ និងអនុស្សរណៈនៃការយោគយល់គ្នា (MoU) ដែលបង្ហាញពីកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើជួញដូរមនុស្សឆ្លងព្រំដែន រួមទាំងការចែករំលែកព័ត៌មាន ការស៊ើបអង្កេត និងការកាត់ទោស ជាមួយប្រទេសឥណ្ឌា ម៉ាឡេស៊ី ចិន ថៃ និងវៀតណាម។ រដ្ឋាភិបាលបានចុះហត្ថលេខាលើ នីតិវិធីប្រតិបត្តិស្តង់ដារ (SOP) ថ្មីមួយជាមួយប្រទេសថៃស្តីពីកិច្ចសហប្រតិបត្តិការលើការអនុវត្តច្បាប់ និងបន្តការចរចា លើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីកិច្ចសហប្រតិបត្តិការផ្នែកប៉ូលិស ជាមួយប្រទេសឥណ្ឌូនេស៊ី។ រដ្ឋាភិបាលបានបន្តសហការជាមួយសហរដ្ឋអាមេរិកតាមរយៈក្រុមការងារអនុវត្តច្បាប់ដែលដែលផ្តោតលើការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត និងឧក្រិដ្ឋកម្មផ្លូវភេទកុមារផ្សេងទៀត។

រដ្ឋាភិបាល ដោយមានកិច្ចសហការជាមួយ និងតាមរយៈការផ្តល់មូលនិធិពីអង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយផ្សេងទៀត បានបង្កើនការបណ្តុះបណ្តាលដល់ប៉ូលីស ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីរដ្ឋាភិបាលផ្សេងទៀតអំពីច្បាប់ប្រឆាំងការជួញដូរ បច្ចេកទេសស៊ើបអង្កេត ការប្រមូលភស្តុតាង គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណ និងការពារជនរងគ្រោះ។ ទោះបីជាមានការបណ្តុះបណ្តាលទាំងនោះក៏ដោយ ប៉ូលីសជាច្រើន ជាពិសេសនៅតាមជនបទ នៅតែមិនទាន់ដឹងពីរបៀបធ្វើការងារប្រឆាំងការជួញដូរនៅឡើយ ព្រោះភាគច្រើនមិនទាន់បានទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសអនុវត្តច្បាប់ជាមូលដ្ឋាននោះទេ។ លើសពីនេះទៀត មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីយុត្តិធម៌ នៅខ្វះឧបករណ៍សម្ភារចាំបាច់ សម្រាប់ដោះស្រាយករណីជួញដូរមនុស្សឱ្យបានសមរម្យ ដោយនេះរួមមានយានយន្ត កុំព្យូទ័រ និងឧបករណ៍ទំនាក់ទំនង និងឧបករណ៍ធ្វើកោសល្យវិច្ច័យផ្សេងៗ។ ជាលទ្ធផល ភាពស្មុគស្មាញផ្នែកបច្ចេកទេសរបស់ឧក្រិដ្ឋជនក្នុងការលាក់បាំង និងបំផ្លាញភស្តុតាងក្នុងអំឡុងពេលចុះបង្ក្រាបរបស់ប៉ូលីស បានធ្វើឱ្យការប្រមូលភស្តុតាងនៅមានកម្រិត និងរារាំងដល់សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការកាត់ទោសជនល្មើស។ រដ្ឋាភិបាលតម្រូវឱ្យផ្តល់មូលនិធិនៃការងារស៊ើបអង្កេតប្រឆាំងការជួញដូរទាំងអស់ត្រូវធ្វើឡើងតាមរយៈការទូទាត់សងវិញតាមពេលក្រោយ ជាហេតុធ្វើឱ្យអង្គភាពប៉ូលិសនីមួយៗត្រូវរ៉ាប់រងការចំណាយពាក់ព័ន្ធផ្សេងៗ ដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួនជាមុន។ អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថា មន្ត្រី

មួយចំនួនបានរង់ចាំជាច្រើនខែសម្រាប់ការទូទាត់សំណងនេះ ដែលពេលខ្លះមិនត្រូវបានសងពេញលេញទេ ហើយបញ្ហាហិរញ្ញវត្ថុជាបន្តបន្ទាប់បានធ្វើឱ្យអង្គភាពនគរបាលមួយចំនួនងាយនឹងមានអំពើពុករលួយ។ អង្គការក្នុងស្រុក និងមន្ត្រីមួយចំនួនបានបន្តសង្កត់ធ្ងន់លើតម្រូវការបន្ទាន់មួយសម្រាប់បច្ចេកទេសប្រមូលភស្តុតាងដ៏ស្មុគស្មាញ រួមទាំងការស៊ើបអង្កេតសម្ងាត់បន្ថែមទៀត ដើម្បីកាត់បន្ថយការពឹងផ្អែកលើសក្ខីកម្មសាក្សី និងបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងរក និងប្រយុទ្ធប្រឆាំងនឹងការជួញដូរផ្លូវភេទ។ មន្ត្រី ក្រសួងយុត្តិធម៌ បានរាយការណ៍ពីការព្រួយបារម្ភរបស់ពួកគេថា ការកែប្រែច្បាប់ ឬចេញបទប្បញ្ញត្តិថ្មី ដើម្បីផ្តល់សិទ្ធិជាពិសេសដល់អាជ្ញាធរស៊ើបអង្កេតសម្ងាត់នៅក្នុងករណីជួញដូរមនុស្ស អាចនាំឱ្យមានការរំលោភបំពានអំណាចពីសំណាក់ប៉ូលីស។

## ការការពារ

រដ្ឋាភិបាលបានបន្តកិច្ចខិតខំប្រឹងប្រែងការពារជនរងគ្រោះ។ រដ្ឋាភិបាល រាយការណ៍ថាបានធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះ ឬបុគ្គលដែលអាចជាជនរងគ្រោះ បានចំនួន ៩២៥នាក់ ក្នុងឆ្នាំ២០២២។ ខណៈដែលច្បាប់បានចែងថាបុគ្គលម្នាក់មិនអាចត្រូវបានកំណត់ថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្សនោះឡើយ ដរាបណាដំណើរការកាត់ក្តីព្រហ្មទណ្ឌមិនទាន់បានបញ្ចប់ជាស្ថាពរដោយមានសាលក្រមតុលាការ រដ្ឋាភិបាលអាចកំណត់ជាផ្លូវការនូវបុគ្គលទាំងនោះថាជា "ជនសង្ស័យថារងគ្រោះ" ដើម្បីអនុញ្ញាតឱ្យពួកគេ ទទួលបានសេវានានា រួមទាំងសេវាផ្លូវច្បាប់។ អាជ្ញាធរបានកំណត់អត្តសញ្ញាណជនរងគ្រោះទាំងអស់នៅមណ្ឌលសំចតប៉ោយប៉ែត ដោយក្នុងនោះមាន ៩១៥នាក់ជាជនជាតិខ្មែរ និង ១០នាក់ជាជនរងគ្រោះបរទេស (៩នាក់មកពីប្រទេសភូមា និង១នាក់មកពីប្រទេសអេហ្ស៊ីប)។ បើធៀបនឹងឆ្នាំមុន ការកំណត់អត្តសញ្ញាណជនរងគ្រោះមានចំនួន ៣៦៤ នាក់។ រដ្ឋាភិបាលបានរាយការណ៍ពីការត្រួតពិនិត្យពលករចំណាកស្រុកជនជាតិខ្មែរ ដែលជាមនុស្សពេញវ័យនិងកុមារចំនួន ៩៧.០៥២ នាក់ដែលត្រឡប់មកពីប្រទេសថៃ។ បើប្រៀបធៀបនឹងឆ្នាំ២០២១ ការត្រួតពិនិត្យលើពលករចំណាកស្រុកមានចំនួន ៨.៣៧០ នាក់ ។ រដ្ឋាភិបាលមិនបានរាយការណ៍ពីការត្រួតពិនិត្យមើលក្រុមជនងាយរងគ្រោះផ្សេងទៀត រួមទាំងកម្មករក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត ដើម្បីរកសូចនាករឬសញ្ញាណនៃអំពើជួញដូរមនុស្សនោះទេ ហើយអ្នកសង្កេតការណ៍បាននិយាយថា រដ្ឋាភិបាលមិនបានត្រួតពិនិត្យកម្មករទាំងនោះទេ។ អ្នកការទូតបរទេសនៅក្នុងរាជធានីបានរាយការណ៍ថាបានទទួលព័ត៌មានរាប់រយដងពីបុគ្គលដែលអាចជាជនរងគ្រោះ ជាប់នៅក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត ស្វែងរកជំនួយ។ មន្ត្រីកម្ពុជា ធ្វើសកម្មភាពនាំបុគ្គលដែលអាចជាជនរងគ្រោះទាំងនោះ ចេញពីបរិវេណ តែក្នុងករណីដែលមន្ត្រីស្ថានទូតបានផ្តល់ព័ត៌មានលម្អិតអំពីទីតាំង និងអត្តសញ្ញាណបុគ្គលដែលអាចជាជនរងគ្រោះទាំងនោះ ។ អ្នកការទូតបរទេសក៏បានរាយការណ៍ថា

អាជ្ញាធរមិនបានកំណត់អត្តសញ្ញាណបុគ្គលដទៃទៀត ដែលអាចជាជនរងគ្រោះ នៅទីតាំងទាំងនេះ ឬបិទប្រតិបត្តិការតាមអ៊ីនធឺណិតទាំងនោះទេ សូម្បីតែបន្ទាប់ពីបានចូលទៅក្នុងទីតាំងទាំងនោះ ហើយបាននាំយកជនរងគ្រោះដែលមានឈ្មោះ ចេញពីទីនោះហើយក៏ដោយ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSAVY) មានគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ប៉ុន្តែការកំណត់អត្តសញ្ញាណជនរងគ្រោះ ការបញ្ជូនបន្ត និងកិច្ចខិតខំប្រឹងប្រែងធ្វើមាតុភូមិនិវត្តន៍របស់ភ្នាក់ងារអនុវត្តច្បាប់ នៅតែមានភាពខុសប្លែកគ្នា និងមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយ ហើយនីតិវិធីរបស់រដ្ឋាភិបាលមិនទាន់មានលក្ខណៈគ្រប់គ្រាន់សម្រាប់ជនរងគ្រោះបរទេសទេ។ អ្នកសង្កេតការណ៍បានរាយការណ៍ថា មន្ត្រីជាញឹកញាប់មិនបានអនុវត្តតាមនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះដែលបានបង្កើតឡើងសម្រាប់ជនរងគ្រោះបរទេសដែលបានរកឃើញពីក្នុងទីតាំងប្រតិបត្តិការឆបោកតាមអ៊ីនធឺណិតទេ ហើយបែរជាបានឃុំខ្លួន និងបញ្ជូនពួកគេចេញដោយមិនពិនិត្យរកសូចនាករការជួញដូរមនុស្ស ឬផ្តល់សេវាសមស្របនោះឡើយ។ រដ្ឋាភិបាលបានចាត់ទុកករណីទាំងនោះភាគច្រើនថាជា "វិវាទការងារ" ជំនួសឱ្យករណីជួញដូរមនុស្ស។ ដោយសារតែកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ អាជ្ញាធរបានដាក់ទោសទណ្ឌជនបរទេសដែលអាចជាជនរងគ្រោះទាំងនោះ ដោយបទល្មើសអន្តោប្រវេសន៍ពួកគេបានប្រព្រឹត្ត ដែលជាលទ្ធផលផ្ទាល់នៃអំពើជួញដូរមនុស្សទៅវិញ។ បុគ្គលដែលអាចជាជនរងគ្រោះមួយចំនួនត្រូវបានគេនាំចេញពីប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតបានអះអាងថា ប៉ូលីសបានប្រាប់ពួកគេថា អាជ្ញាធរនឹងមិនអនុញ្ញាតឱ្យពួកគេត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេវិញទេ ប្រសិនបើពួកគេរាយការណ៍ជាផ្លូវការអំពីការកេងប្រវ័ញ្ចរបស់ពួកគេ។ ផ្ទុយទៅវិញ អាជ្ញាធរបានណែនាំពួកគេឱ្យនិយាយថា ពួកគេចង់ឈប់ពីការងាររបស់ពួកគេនៅក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតនោះ។

មន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (កសអយ) បានអមដំណើរប៉ូលីសជាទៀងទាត់ក្នុងអំឡុង សកម្មភាពអនុវត្តច្បាប់ ដូចជាក្នុងអំឡុងប្រតិបត្តិការចុះបង្ក្រាប ដើម្បីផ្តល់ជំនួយដល់បុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះ ។ ប្រសិនបើពួកគេមិនមានវត្តមានទេ ប៉ូលីសអាចពិនិត្យរកសូចនាករនៃការជួញដូរ និងបញ្ជូនជនរងគ្រោះទៅ កសអយ ។ ទោះបីជាយ៉ាងណាក៏ដោយ មន្ត្រី កសអយ បានរាយការណ៍ថា ពួកគេមិនបានចូលរួមក្នុងសកម្មភាពអនុវត្តច្បាប់ដែលមានការសម្របសម្រួលណាមួយពាក់ព័ន្ធនឹងទីតាំងដែលមានប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតនោះទេ រួមទាំងនៅក្នុងប្រតិបត្តិការក្រុមការងារពិសេសខ្នាតធំដែលក្រសួងយុត្តិធម៌បានចាប់ផ្តើមឡើងនៅក្នុងខែសីហា ឆ្នាំ២០២២ ក៏មិនដែលបានចូលរួមដែរ ។ អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថាអង្គភាពប្រឆាំងល្បែងពាណិជ្ជកម្ម បានដឹកនាំសកម្មភាពប្រតិបត្តិការភាគច្រើនដើម្បីយកជនដែលអាចជាជនរងគ្រោះ ចេញពីទីតាំងទាំងនោះ កម្រពិនិត្យរកករណីជួញដូរមនុស្ស ហើយក៏មិនបានសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច ដើម្បីដាក់ជនរងគ្រោះនៅក្នុងមណ្ឌលដែរ។ ផ្ទុយទៅវិញ អាជ្ញាធរបាន

ចាត់បុគ្គលដែលអាចជាជនរងគ្រោះទាំងនោះ ថាជាជនអន្តោប្រវេសន៍មិនប្រក្រតី ឬជាដើមបណ្តឹងរដ្ឋប្បវេណី។ ជួនកាលប៉ូលីសមូលដ្ឋានបានបញ្ជូនជនរងគ្រោះទៅអង្គការក្រៅរដ្ឋាភិបាលដោយផ្ទាល់ ហើយបានរាយការណ៍ថា ដំណើរការបញ្ជូនបន្តមានភាពរហ័ស ហើយជនរងគ្រោះអាចចូលទៅកាន់មណ្ឌលដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងរយៈពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការកំណត់អត្តសញ្ញាណ។ ទោះបីជាមានដំណើរការនេះក៏ដោយ រដ្ឋាភិបាលបានបន្តអនុវត្តបទប្បញ្ញត្តិដែលរារាំងអង្គការមិនមែនរដ្ឋាភិបាលពីការតំណាងឱ្យបុគ្គលដែលស្វែងរកការទទួលស្គាល់ជាផ្លូវការថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ក្រោមការរៀបចំនេះ អាជ្ញាធរតម្រូវឱ្យជនរងគ្រោះស្វែងរកអត្តសញ្ញាណជាផ្លូវការពីក្រសួងមហាផ្ទៃដើម្បីទទួលបានសេវាការពារ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ពីការខ្វះខាតកិច្ចសហប្រតិបត្តិការពីអាជ្ញាធរ ដែលរារាំងដល់ប្រតិបត្តិការរបស់ពួកគេ។ នីតិវិធីបញ្ជូនបន្តរបស់រដ្ឋាភិបាលមិនទាន់មានលក្ខណៈគ្រប់គ្រាន់សម្រាប់ជួយដល់ជនបរទេសដែលអាចជាជនរងគ្រោះ ដែលត្រូវបានសង្គ្រោះពីទីតាំងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតនៅឡើយ។ ជារឿយៗអាជ្ញាធរបានចាត់ទុកជនរងគ្រោះជាជនបរទេស ថាជាជនអន្តោប្រវេសន៍មិនប្រក្រតី ហើយដាក់ពួកគេនៅក្នុងកន្លែងឃុំខ្លួន។

ក្រសួងសង្គមកិច្ច បានបន្តដំណើរការមណ្ឌលសំចតព្រំដែននៅប៉ោយប៉ែត ហើយ ក្រសួងមហាផ្ទៃបានដំណើរការមណ្ឌលសំចតពលករចំណាកស្រុកមួយទៀតនៅក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។ អាជ្ញាធរបានផ្តល់សេវាធ្វើសមាហរណកម្មឡើងវិញ និងបញ្ជូនបន្តទៅកាន់មណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល នូវជនរងគ្រោះជនជាតិខ្មែរមួយចំនួនដែលមិនបានរាយការណ៍។ រដ្ឋាភិបាលក៏បានបញ្ជូនជនរងគ្រោះជាជនបរទេសទាំង១០នាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅមណ្ឌលសំចតប៉ោយប៉ែត ទៅកាន់អង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់សេវាមុនពេលធ្វើមាតុភូមិនិវត្តន៍។ ក្រសួងសង្គមកិច្ច បានរាយការណ៍ថា ក្រសួងបានផ្តល់សេវាដល់ជនរងគ្រោះកម្ពុជាចំនួន ២៩០នាក់ និងជនដែលសង្ស័យថារងគ្រោះដោយការជួញដូរ ដែលបានត្រឡប់មកពីបរទេស រួមមានពីប្រទេសចិន ថៃ ម៉ាឡេស៊ី វៀតណាម និងនីហ្សេរីយ៉ា។ រដ្ឋាភិបាលក៏បានបញ្ជូនជនរងគ្រោះចំនួន ២.២២៧នាក់ និងជនសង្ស័យថាជាជនរងគ្រោះនៃការជួញដូរទៅទទួលសេវាសង្គមដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល។ ក្រសួងមិនបានរាយការណ៍ថាចំនួនប៉ុន្មាននាក់ក្នុងចំណោមជនរងគ្រោះទាំងនោះជាជនបរទេសនោះទេ។ រដ្ឋាភិបាលបានផ្តល់សេវាសមាហរណកម្មឡើងវិញដល់ជនរងគ្រោះកម្ពុជាចំនួន ៩១នាក់ និងជន"សង្ស័យ"ថារងគ្រោះឱ្យត្រឡប់ទៅសហគមន៍របស់ពួកគេវិញ។ បើប្រៀបធៀបក្នុងឆ្នាំ២០២១ ក្រសួងសង្គមកិច្ច បានផ្តល់សេវាដល់ជនរងគ្រោះពីការជួញដូរមនុស្សទាំងខ្មែរ និងបរទេសចំនួន៤០៤នាក់។ រដ្ឋាភិបាលអាចផ្តល់ដល់ជនរងគ្រោះនូវប្រាក់ឧបត្ថម្ភសម្រាប់អាហារ ប្រាក់ឧបត្ថម្ភសម្រាប់ការចំណាយក្នុងការរស់នៅរយៈពេលបីខែ ការបណ្តុះបណ្តាលការងារ និងជំនួយក្នុងការធ្វើសមាហរណកម្ម ប៉ុន្តែ ដូចនៅក្នុងរបាយការណ៍មុនដែរ ក្រសួងសង្គមកិច្ច ពឹងផ្អែកយ៉ាងខ្លាំង

លើជំនួយហិរញ្ញវត្ថុពីអង្គការក្រៅរដ្ឋាភិបាល ដើម្បីគ្របដណ្តប់លើសេវាកម្មទាំងនោះ។ រដ្ឋាភិបាលមិនមានសមត្ថភាព ឬធនធានដែលអាចផ្តល់សេវាការពារគ្រប់គ្រាន់ រួមទាំងទីជម្រកដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនោះទេ។ ដូច្នេះហើយ រដ្ឋាភិបាលបានបន្តពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រទេសម្ចាស់ជំនួយ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់ ឬគាំទ្រការផ្តល់សេវាទាំងនោះដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ក្រសួងសង្គមកិច្ច បានបន្តគោលការណ៍ណែនាំដែលបង្ហាញពីស្តង់ដារអប្បបរមាសម្រាប់ការស្នាក់នៅក្នុងមណ្ឌល របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ក្រសួងសង្គមកិច្ច ក៏បានគ្រប់គ្រងការថែទាំរយៈពេលវែង និងជំនួយផ្សេងៗ សម្រាប់ជនរងគ្រោះជាកុមារដែលមិនអាចធ្វើសមាហរណកម្មទៅក្នុងសហគមន៍របស់ពួកគេឡើងវិញផងដែរ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលមិនបានជួយសម្រួលដល់ការផ្ទេរជាផ្លូវការនូវអំណាចមេបា ចំពោះជនរងគ្រោះពីការជួញដូរកុមារ ទៅឱ្យអង្គការក្រៅរដ្ឋាភិបាលទេ ដោយការណ៍នេះអាចធ្វើឱ្យអង្គការក្រៅរដ្ឋាភិបាលដែលទទួលយកជនរងគ្រោះកុមារឱ្យមកទទួលការថែទាំ ងាយរងនូវចំណាត់ការរបស់តុលាការ។ បទប្បញ្ញត្តិដែលអនុញ្ញាតឱ្យមានការទូទាត់ផ្នែកហិរញ្ញវត្ថុជំនួសឱ្យការកាត់ទោសដ៏តឹងរ៉ឹងបានរារាំងមិនឱ្យគ្រួសារមួយចំនួនយល់ព្រមឱ្យមានអាណាព្យាបាលបណ្តោះអាសន្ននៅមណ្ឌល។ ដោយគ្មានការយល់ព្រមពីគ្រួសារ មន្ត្រីរដ្ឋាភិបាល ពេលខ្លះបានបញ្ជូនកុមារទៅកាន់បរិយាកាសដែលមានហានិភ័យខ្ពស់ ដោយទុកឱ្យពួកគេងាយរងគ្រោះក្នុងការក្លាយជាជនរងគ្រោះជាថ្មីឡើងវិញ។ រដ្ឋាភិបាលបានអនុញ្ញាតឱ្យគ្រឹះស្ថានសុខាភិបាលសាធារណៈផ្តល់សេវាព្យាបាលដោយមិនគិតថ្លៃដល់ពលករចំណាកស្រុកទាំងអស់នៅក្នុងប្រទេសកម្ពុជា រួមទាំងជនបរទេសដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្សផងដែរ។ គោលនយោបាយនេះបានសម្រាលបន្ទុកផ្នែកហិរញ្ញវត្ថុរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការផ្តល់ការថែទាំសុខភាពដល់ប្រជាជនដែលងាយរងគ្រោះ។ សេវារបស់រដ្ឋាភិបាលមានកម្រិត ដោយរួមមានទាំងទីជម្រកសម្រាប់បុរសដែលជាជនរងគ្រោះដោយការជួញដូរកម្លាំងពលកម្ម ។ ទោះយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានបន្តសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់សេវាដល់ជនរងគ្រោះជាបុរសដែលរងគ្រោះដោយការកេងប្រវ័ញ្ចក្នុងឧស្សាហកម្មនេសាទនៅប្រទេសថៃ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) ក៏បានផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីផ្សេងទៀតដើម្បីផ្តល់ឱកាសការងារដល់បុរសដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងឧស្សាហកម្មនេសាទ ប៉ុន្តែក្រសួងមិនបានរាយការណ៍ថា តើមានជនរងគ្រោះប៉ុន្មាននាក់ដែលទទួលបានអត្ថប្រយោជន៍ពីកម្មវិធីទាំងនោះទេ។ អ្នកផ្តល់សេវាពីអង្គការក្រៅរដ្ឋាភិបាល បានកត់សម្គាល់ពីកង្វះខាតយ៉ាងធ្ងន់ធ្ងរនៃសេវាធ្វើសមាហរណកម្ម និងវប្បធម៌មាក់ងាយពាក់ព័ន្ធនឹងបទពិសោធន៍នៃភាពរងគ្រោះដោយការកេងប្រវ័ញ្ចកម្លាំងពលកម្មនៅសមុទ្រ ដែលការមាក់ងាយទាំងនោះបានបណ្តាលឱ្យមានការជួញដូរឡើងវិញចំពោះអតីតពលករនេសាទដែលបានវិលត្រឡប់ទៅផ្ទះវិញទៅហើយ។

រដ្ឋាភិបាលបានបន្តផ្តល់ការថែទាំជាមូលដ្ឋានក្នុងការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះកម្ពុជាដែលត្រូវបានកេងប្រវ័ញ្ចនៅក្រៅប្រទេស ប៉ុន្តែរដ្ឋាភិបាលពឹងផ្អែកលើអង្គការម្ចាស់ជំនួយដើម្បីផ្តល់ជំនួយហិរញ្ញវត្ថុក្នុងការធ្វើមាតុភូមិនិវត្តន៍។ បេសកកម្មការទូតកម្ពុជានៅក្រៅប្រទេសក៏ខ្វះខាតថវិកា និងសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់ជំនួយជាមូលដ្ឋានដល់ជនរងគ្រោះ ឬធ្វើមាតុភូមិនិវត្តន៍។ ជនរងគ្រោះមួយចំនួនត្រូវបានគេរាយការណ៍ថា មិនអាចទទួលបានជំនួយពីសេវាកុងស៊ុលកម្ពុជានៅក្រៅប្រទេស ដោយសារលេខទូរស័ព្ទទាន់ហេតុការណ៍មិនមានអ្នកទទួល និងបុគ្គលិកមិនបានឆ្លើយតបទាន់ពេល។ ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងប្រទេសដែលគ្មានតំណាងការទូតកម្ពុជា មានឱកាសកាន់តែតិចតួចទៅទៀតក្នុងការទទួលបានសេវាគាំទ្រ។ រដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយប្រទេសថៃសម្រេចលើ នីតិវិធីប្រតិបត្តិស្តង់ដារ (SOP) ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ នៅឆ្នាំ២០២២ ក្រសួងមហាផ្ទៃមិនបានរាយការណ៍ពីការធ្វើការងារជាមួយអាជ្ញាធរប្រទេសចិនក្នុងការធ្វើមាតុភូមិនិវត្តន៍ស្ត្រីកម្ពុជាដែលត្រូវបានជ្រើសរើសតាមរយៈការសន្យាការងារក្លែងក្លាយនៅក្នុងប្រទេសចិន ហើយត្រូវបានបង្ខំឱ្យរៀបការជាមួយជនជាតិចិន។ បើប្រៀបធៀបនឹងឆ្នាំ២០២១ ការធ្វើមាតុភូមិនិវត្តន៍ស្ត្រីកម្ពុជាមានជាង ៣០០នាក់ដែលភាគច្រើនទំនងជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

រដ្ឋាភិបាលតម្រូវឱ្យធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះជាជនបរទេស លើកលែងតែក្នុងករណីកម្រមួយចំនួន ហើយមិនមានជម្រើសផ្លូវច្បាប់ក្នុងការបញ្ជូនបុគ្គលនោះទៅកាន់ប្រទេសដែលពួកគេអាចប្រឈមមុខនឹងការធ្វើបាប ឬបញ្ហាលំបាកផ្សេងៗ។ ខណៈពេលដែលគោលនយោបាយរបស់រដ្ឋាភិបាលពីមុនបានធានាឱ្យជនរងគ្រោះជនបរទេសដែលកំពុងរង់ចាំការធ្វើមាតុភូមិនិវត្តន៍អាចស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល រដ្ឋាភិបាលមិនបានកំណត់អត្តសញ្ញាណបុគ្គល ដែលអាចជាជនរងគ្រោះ ដែលត្រូវបានគេនាំចេញពីទីតាំងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតនោះទេ ហើយធ្វើឱ្យពួកគេមិនអាចស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលអង្គការក្រៅរដ្ឋាភិបាលបានឡើយ។ រដ្ឋាភិបាលបានរាយការណ៍ថាបានឃុំខ្លួនមនុស្សចំនួន ៩២០នាក់ មកពីប្រទេសចំនួន ១៩ ដែលជាផ្នែកមួយនៃប្រតិបត្តិការក្រុមការងារពិសេសរបស់ក្រសួងយុត្តិធម៌ដែលចាប់ផ្តើមកាលពីខែសីហា ឆ្នាំ២០២២ ដែលបានលើកឡើងពីខាងដើម។ រដ្ឋាភិបាលមិនបានផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់ការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះទាំងនោះទេ ផ្ទុយទៅវិញ ស្ថានទូតរៀងៗខ្លួនរបស់ជនរងគ្រោះបរទេសទាំងនោះបានផ្តល់មូលនិធិសម្រាប់ការធ្វើមាតុភូមិនិវត្តន៍របស់ពួកគេ។ ប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ថាប៉ូលីសបានទាមទារឱ្យជនរងគ្រោះដែលនៅក្នុងកន្លែងឃុំឃាំង បង់ថ្លៃសេវាមូលដ្ឋាន រួមមានទាំងអាហារ ហើយថែមទាំងទាមទារឱ្យបង់ប្រាក់ សម្រាប់ការដោះលែងជនរងគ្រោះពីការឃុំឃាំងទៀតផង។ ជនរងគ្រោះខ្លះបានអះអាងថាពួកគេបានចំណាយប្រាក់៥ដុល្លារសម្រាប់អាហារ និង១.០០០-៣.០០០ដុល្លារសម្រាប់ការដោះលែងពួកគេពី

កន្លែងឃុំឃាំង។ ប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ថារដ្ឋាភិបាលបានសហការជាមួយអាជ្ញាធរបរទេសដូចជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងតៃវ៉ាន់ដើម្បីធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះពីប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត។

រដ្ឋាភិបាលមិនតម្រូវឱ្យជនរងគ្រោះដោយអំពើជួញដូរមនុស្សចូលរួមក្នុងការស៊ើបអង្កេតការជួញដូរ ឬការកាត់ទោស ដើម្បីទទួលបានសេវាការពារនោះទេ។ អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថា មេធាវីដែលតែងតាំងដោយរដ្ឋាភិបាលមិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះករណីជួញដូរទេ ដោយសាររដ្ឋាភិបាលមិនបានផ្តល់ប្រាក់ឧបត្ថម្ភដល់ពួកគេ សម្រាប់ការងាររបស់ពួកគេលើករណីទាំងនោះ។ ជនរងគ្រោះខ្លះបានជួបជាមួយមេធាវីរបស់ពួកគេតែនៅក្នុងថ្ងៃសវនាការប៉ុណ្ណោះ។ មិនមានបទប្បញ្ញត្តិផ្លូវច្បាប់សម្រាប់ផ្តល់លិខិតអនុញ្ញាតការងារ ការស្នាក់នៅបណ្តោះអាសន្ន ឬឋានៈអន្តោប្រវេសន៍ផ្សេងទៀតដល់ជនរងគ្រោះជាជនបរទេសដែលមានបំណងបន្តស្នាក់នៅក្នុងប្រទេសកម្ពុជា ដើម្បីបន្តចូលរួមក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌនោះទេ។ ដូចក្នុងឆ្នាំមុនៗដែរ ប្រព័ន្ធតុលាការខ្សោយ និងពុករលួយរបស់កម្ពុជា និងកង្វះការការពារជនរងគ្រោះ និងការការពារសាក្សី ដែលធ្វើឱ្យដំណើរការកាត់ក្តីកាន់តែមានរយៈពេលយូរបន្ថែមទៀត រួមទាំងការភ័យខ្លាចមានការសងសឹកពីសំណាក់ជនល្មើសជួញដូរ បានរារាំងដល់ឆន្ទៈរបស់ជនរងគ្រោះក្នុងការសហការក្នុងករណីជាច្រើន។ អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថាជនរងគ្រោះចូលចិត្តការដោះស្រាយក្រៅប្រព័ន្ធតុលាការជាជាងធ្វើតាមដំណើរការតុលាការដែលនេះជាមធ្យោបាយលឿនបំផុតដើម្បីទទួលបានសំណងជាថវិកា។ សំណងមានភាពលំបាកក្នុងការទទួលបានដោយសារតែតម្រូវការផ្លូវច្បាប់ដែលពន្យារពេលក្នុងការទូទាត់រហូតដល់បន្ទាប់ពីការបញ្ចប់ការជាប់ពន្ធនាគាររបស់ជនល្មើស។ ការគេចខ្លួនជាញឹកញាប់របស់ជនល្មើសជួញដូរ ធ្វើឱ្យកាន់តែមានភាពស្មុគស្មាញខ្លាំងឡើងដល់ដំណើរការនេះ។ អ្នកសង្កេតការណ៍បានកត់សម្គាល់ថា ប្រទេសកម្ពុជានៅខ្វះ SOP ដើម្បីកំណត់របៀបគណនាប្រាក់សំណង ឬសំណងផ្សេងៗ។ ជនរងគ្រោះកម្រទទួលបានចំនួនទឹកប្រាក់ដែលបានសន្យាណាស់ ហើយគ្រួសារជនរងគ្រោះជាច្រើនបានដោះស្រាយក្រៅប្រព័ន្ធតុលាការជាមួយជនល្មើសជួញដូរ ឬទទួលយកសំណូកដើម្បីទម្លាក់ការចោទប្រកាន់ពាក់ព័ន្ធនានា។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលចំនួនពីរ ហើយទទួលបានសំណងចំនួន 9.300 ដុល្លារសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅឆ្នាំ ២០២២។ អង្គការក្រៅរដ្ឋាភិបាលក៏បានរាយការណ៍ផងដែរថា ចៅក្រមមិនទាន់មានចំណេះដឹងគ្រប់គ្រាន់អំពីវិធីសាស្រ្តដែលផ្តោតលើជនរងគ្រោះ និងបញ្ចៀសពីការប៉ះទង្គិចផ្លូវចិត្ត ដើម្បីទទួលបានការចូលរួមរបស់ជនរងគ្រោះនៅក្នុងបន្ទប់សវនាការឡើយ។ ការណ៍នេះបាននាំអោយមានការប៉ះទង្គិចផ្លូវចិត្តឡើងវិញទាំងកុមារ និងជនរងគ្រោះដែលជាមនុស្សពេញវ័យ ។

# ការបង្ការទប់ស្កាត់

រដ្ឋាភិបាលបានបន្តកិច្ចខិតខំប្រឹងប្រែងបង្កាទប់ស្កាត់។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអគ្គលេខាធិការដ្ឋានរបស់ខ្លួនបានសម្របសម្រួលសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស បន្តអនុវត្តផែនការសកម្មភាពជាតិប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០១៩-២០២៣ និងបានបញ្ចប់ការវាយតម្លៃពាក់កណ្តាលអាណត្តិរបស់ផែនការសកម្មភាពជាតិ ។ រដ្ឋាភិបាលបានផ្សព្វផ្សាយលទ្ធផលនៃការពិនិត្យវាយតម្លៃជាសាធារណៈ ដែលបានរកឃើញថាអាជ្ញាធរថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិមិនទាន់បានសម្របសម្រួលឱ្យបានគ្រប់គ្រាន់នៅឡើយទេ រដ្ឋាភិបាលមិនបានផ្តល់ធនធានគ្រប់គ្រាន់សម្រាប់សកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស ហើយការទទួលខុសត្រូវរបស់អន្តរក្រសួង-ស្ថាប័នមានការត្រួតស៊ីគ្នា។ គជបជ បានផលិតរបាយការណ៍ប្រចាំឆ្នាំដែលចងក្រងឯកសារអំពីកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើជួញដូរមនុស្ស របស់រដ្ឋាភិបាល។ គជបជ បានផ្សព្វផ្សាយរបាយការណ៍នេះជាសាធារណៈ។ គជបជ បានដឹកនាំកិច្ចប្រជុំចំនួន ៣៤៤ ក្នុងឆ្នាំ២០២២ ជាមួយក្រសួងផ្សេងៗ ដើម្បីលើកកម្ពស់សារៈសំខាន់នៃបញ្ហាជួញដូរមនុស្សនៅក្នុងរដ្ឋាភិបាល បើធៀបនឹងឆ្នាំ២០២១ គឺមានចំនួន ២៧៤។ គជបជ បានអញ្ជើញអ្នករួចរស់ជីវិតពីអំពើជួញដូរមនុស្សឱ្យចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាដើម្បីកែលម្អគោលនយោបាយតាមរយៈអ្នកជំនាញ និងអនុសាសន៍របស់អ្នករួចរស់ពីអំពើជួញដូរមនុស្ស។ លេខាធិការដ្ឋាន គជបជ បានបន្តក្រុមការងារចំនួន៦ ដើម្បីតាមដានកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការអន្តរក្រសួងស្ថាប័ន ក៏ដូចជាក្រុមការងារនៃគណៈកម្មាធិការខេត្តរបស់ខ្លួន។ គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គខបជ) ចំនួនបួន បន្តទទួលបានមូលនិធិពីរដ្ឋាភិបាលមជ្ឈិមតិចតួច បានសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនៅថ្នាក់មូលដ្ឋានដើម្បីអនុវត្តសកម្មភាពដែលមាននៅក្នុងផែនការសកម្មភាពជាតិ ។ គខបជ នីមួយៗបានបន្តអនុវត្តផែនការសកម្មភាពតាមថ្នាក់ខេត្ត ដោយបង្ហាញពីរបៀបរាយការណ៍ករណីជួញដូរទៅប៉ូលីស កិច្ចខិតខំប្រឹងប្រែងការពារជនរងគ្រោះ និងសកម្មភាពបង្ការទប់ស្កាត់នានា។ គជបជ និង គខបជ ជាច្រើន ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័ន និងដៃគូអង្គការក្រៅរដ្ឋាភិបាល បានបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាលស្តីពីច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស បច្ចេកទេសស៊ើបអង្កេត ការប្រមូលភស្តុតាង យុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការការពារសិទ្ធិជនរងគ្រោះ ការការពារកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការធ្វើមាតុភូមិនិវត្តន៍របស់បុគ្គលដែលសង្ស័យថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ក្រុមការងារត្រួតពិនិត្យ (MWG) បានបន្តពង្រឹងការងាររបស់ គជបជ នៅថ្នាក់ខេត្ត ដោយបានជួបជាមួយមន្ត្រីថ្នាក់ខេត្ត និងវាយតម្លៃលើចំណុចដែលគួរកែលម្អ។ រដ្ឋាភិបាលបានបណ្តុះបណ្តាលមន្ត្រីការទូតកម្ពុជាស្តីពីអំពើជួញដូរមនុស្សជាផ្នែកមួយនៃការតម្រង់ទិសមុនពេលចេញទៅបំពេញភារកិច្ចនៅក្រៅប្រទេស។ រដ្ឋាភិបាលមិនបានរាយការណ៍អំពីថវិកា

ប្រឆាំងអំពើជួញដូរមនុស្សរបស់ខ្លួនក្នុងឆ្នាំ២០២២នោះទេ នៅក្នុងឆ្នាំ២០២០ រដ្ឋាភិបាលមានថវិកាចំនួនប្រមាណ ២,២ ពាន់លានរៀល (៥៤៣.០៨០ ដុល្លារ) ដែលជាឆ្នាំចុងក្រោយដែលមានទិន្នន័យ។ អង្គការក្រៅរដ្ឋាភិបាល បានរាយការណ៍ពីការផ្តល់មូលនិធិដ៏តិចតួចរបស់រដ្ឋាភិបាលសម្រាប់សកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស ហើយ បាននាំឱ្យអង្គការក្រៅរដ្ឋាភិបាលមួយចំនួនចំណាយលើសកម្មភាពរបស់រដ្ឋាភិបាល។ រដ្ឋាភិបាល ដោយមានកិច្ច សហការជាមួយម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលនានា បានផ្សព្វផ្សាយព័ត៌មានអំពីច្បាប់ប្រឆាំងការជួញដូរ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ពលកម្មកុមារ និងយុទ្ធសាស្ត្រក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ មន្ត្រីអនុវត្តច្បាប់ មន្ត្រីរដ្ឋាភិបាលផ្សេងទៀត និងប្រជាជនទូទៅ។ រដ្ឋាភិបាលបានផ្សព្វផ្សាយសារលើកកម្ពស់ការ យល់ដឹងអំពីការប្រឆាំងការជួញដូរមនុស្សចំនួន 202,518 នៅទូទាំងប្រទេស រួមទាំងការផ្សាយតាមវិទ្យុ និងបាន បញ្ចូលទៅក្នុងព្រឹត្តិការណ៍សាធារណៈរាប់ពាន់ (ដូចជាសាលាក្រុង និងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ និងរួមទាំង ការផ្សាយតាមទូរទស្សន៍ និងវិទ្យុ ស្តីពីទិវាជាតិប្រឆាំងអំពើជួញដូរមនុស្ស និងព្រឹត្តិការណ៍តាមសាលារដ្ឋ) និងមាន មន្ត្រីជាន់ខ្ពស់ថ្លែងជាសាធារណៈអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ មន្ត្រីជាន់ខ្ពស់បានទទួលស្គាល់ទំហំ នៃប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត និងវត្តមាននៃជនបរទេសដែលរងគ្រោះដោយអំពើជួញដូរមនុស្សនៅ កម្ពុជា។ នៅឆ្នាំ 2022 ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានដាក់បញ្ចូលសារប្រឆាំងការជួញដូរទៅក្នុងពិធីអបអរ សាទរទិវាវប្បធម៌ជាតិ គជបជ បានដំណើរការយុទ្ធនាការលើកកម្ពស់ការយល់ដឹងដល់គ្រូបង្រៀនដោយផ្តោតលើ សុវត្ថិភាពអ៊ីនធឺណិតសម្រាប់កុមារ និងការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត (OCSE) ហើយក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាល បានបន្តអនុវត្តកម្ម វិធីសិក្សារបស់សាលា ដើម្បីអប់រំសិស្សអំពីហានិភ័យនៃចំណាកស្រុក និងពលកម្មកុមារ។

ប៉ូលីសប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន (AHTJP) និង ក្រសួងមហាផ្ទៃ បានបន្តប្រតិបត្តិ ការបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ ដើម្បីរាយការណ៍អំពីឧក្រិដ្ឋកម្មជួញដូរមនុស្ស។ រដ្ឋាភិបាលមិនបានរាយ ការណ៍អំពីចំនួននៃការហៅទូរសព្ទដែលបានទទួល (បើធៀបនឹងការហៅទូរសព្ទចំនួន ក្នុងឆ្នាំ 2021 មានចំនួន ២១ដង) ហើយមិនបានរាយការណ៍ថាតើការហៅទូរសព្ទណាមួយដែលនាំឱ្យឈានដល់ការស៊ើបអង្កេតអំពើជួញ ដូរ ឬការកំណត់អត្តសញ្ញាណជនរងគ្រោះនោះទេ។ រដ្ឋាភិបាលបានរាយការណ៍ពីការកើនឡើងនៃការចូលរួមតាមរ យៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងគេហទំព័រនគរបាលជាតិកម្ពុជា ដែលបានទទួលពាក្យបណ្តឹងជាង ៦០០ នៃការ សង្ស័យពីការជួញដូរមនុស្ស។ ក្នុងចំណោមបណ្តឹងទាំងនោះ ៤៩៦ ត្រូវបានទទួលក្នុងអំឡុងពេលប្រតិបត្តិការ ៣ ខែប្រឆាំងនឹងការបោកប្រាស់តាមអ៊ីនធឺណិតដែលបានចាប់ផ្តើមនៅក្នុងខែសីហា ឆ្នាំ២០២២។ រដ្ឋាភិបាលមិនបាន រាយការណ៍ថាតើពាក្យបណ្តឹងទាំងនោះនាំឱ្យមានការស៊ើបអង្កេត ការកំណត់អត្តសញ្ញាណជនរងគ្រោះ ឬការ បញ្ជូនទៅដល់ការទទួលសេវាកម្មនោះទេ។ ក្រសួងការងារ និងក្រសួងការបរទេសបានដំណើរការបណ្តាញទូរស័ព្ទ

ទាន់ហេតុការណ៍សម្រាប់ពលរដ្ឋខ្មែរដែលធ្វើការនៅក្រៅប្រទេស ដើម្បីស្វែងរកជំនួយ និងរាយការណ៍ករណីជួញដូរមនុស្ស ប៉ុន្តែមិនបានរាយការណ៍ថា ស្ថានទូតកម្ពុជាបានទទួលទូរស័ព្ទហៅចូលចំនួនប៉ុន្មានក្នុងអំឡុងឆ្នាំ ២០២២ នោះទេ។

ក្រុមអ្នកសង្កេតការណ៍បានរាយការណ៍ថា មន្ត្រីបានដាក់សម្ពាធលើអង្គការក្រៅរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយសាធារណៈ មិនឱ្យពិភាក្សា ឬរាយការណ៍អំពីឧក្រិដ្ឋកម្មជួញដូរមនុស្សនោះទេ។ រដ្ឋាភិបាលបានដកហូតអាជ្ញាប័ណ្ណសារព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមួយដែលគេដឹងថាបានផ្សាយរបាយការណ៍រិះគន់លើប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតក្នុងប្រទេសកម្ពុជា នៅក្នុងអត្ថបទព័ត៌មានដែលមិនពាក់ព័ន្ធនឹងការជួញដូរមនុស្ស។

រដ្ឋាភិបាលមិនបានហាមឃាត់ការដាក់ប្រាក់ឈ្នួលជ្រើសរើសបុគ្គលិក ឬថ្លៃដាក់ឱ្យចូលធ្វើការងារនោះទេ។ អ្នកសង្កេតការណ៍បានកត់សម្គាល់ពីការចំណាយខ្ពស់ តម្រូវការរដ្ឋបាលដ៏ស្មុគស្មាញ និងការដាក់កំហិតដែលមាននៅក្នុងដំណើរការធ្វើចំណាកស្រុកជាផ្លូវការ បានជំរុញឱ្យពលករកម្ពុជាភាគច្រើនបន្តស្វែងរកផ្លូវក្រៅផ្លូវការ ទៅធ្វើការនៅបរទេស។ ក្រសួងការងារ បានបណ្តុះបណ្តាល ភ្នាក់ងារ និងអ្នកជ្រើសរើសពលករ ស្តីពីការអនុវត្តការជ្រើសរើសបុគ្គលិកប្រកបដោយក្រមសីលធម៌ ដើម្បីការពារសិទ្ធិរបស់ពលករចំណាកស្រុក។ រដ្ឋាភិបាលបានធ្វើអធិការកិច្ចចំនួន ៥៤ លើក ផ្តោតលើភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលក្នុងនោះមាន ១០ដង នៅតាមឡឥដ្ឋ ៨ដងនៅសហគ្រាសកសិកម្ម ៧ដងនៅតាមរោងចក្រ និងក្រៅពីនោះគឺនៅក្នុងវិស័យអាជីវកម្មផ្សេងទៀត។ ក្រសួងការងារ ពិន័យជាប្រាក់លើសហគ្រាសមួយដោយសារមិនគោរពច្បាប់ការងារ។ ក្រសួងការងារ បានបន្តឱ្យមានការិយាល័យនៅថ្នាក់ខេត្ត ដើម្បីត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសពលករ និងដោះស្រាយបណ្តឹងរបស់កម្មករ រួមទាំងអំពើជួញដូរមនុស្សដែលអាចកើតមាន។ ទោះយ៉ាងណាក៏ដោយ ក្រសួងមិនបានរាយការណ៍ពីចំនួនបណ្តឹងដែលការិយាល័យទាំងនេះបានទទួលក្នុងឆ្នាំ ២០២២ នោះទេ។ រដ្ឋាភិបាលក៏មិនបានធ្វើអធិការកិច្ចភ្នាក់ងារជ្រើសរើសពលករដែលត្រូវបានចោទប្រកាន់ថាជាប់ពាក់ព័ន្ធក្នុងឧក្រិដ្ឋកម្មជួញដូរមនុស្សនោះទេ។ នៅក្នុងខែធ្នូ ឆ្នាំ ២០២២ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការអន្តរក្រសួងដែលដឹកនាំដោយ ក្រសួងមហាផ្ទៃ និង ក្រសួងការងារ ដើម្បីពង្រឹងការធ្វើអធិការកិច្ចលើអាជីវកម្មដែលជួលកម្មករបរទេស រួមទាំងការត្រួតពិនិត្យលើអាជីវកម្ម កាស៊ីណូ និងក្លឹបដែលមានល្បែងស៊ីសងខុសច្បាប់ ការក្លែងបន្លំតាមអ៊ីនធឺណិត ការជួញដូរកម្លាំងពលកម្ម ការជួញដូរផ្លូវភេទ ឬការលាងលុយ ដែលត្រូវបានគេរាយការណ៍។ ការផ្លាស់ប្តូរក្នុងការធ្វើអធិការកិច្ចទាំងនោះមិនត្រូវបានគេអនុវត្តក្នុងអំឡុងឆ្នាំរបាយការណ៍ទេ។

ក្រសួងការងារ បានរាយការណ៍ថា ខ្លួនបានធ្វើការណែនាំតម្រង់ទិសមុនចេញដំណើរចំនួន៤៩៨ លើក ដល់ប្រជាពលរដ្ឋខ្មែរចំនួន ២៥.២២៤ នាក់ដែលធ្វើចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេសក្នុងនោះមានស្ត្រីចំនួន 9,949 នាក់នៅចន្លោះខែមករាដល់ខែធ្នូ ឆ្នាំ 2022។ យោងតាមអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលធ្វើការលើការប្រឆាំងអំពើជួញដូរមនុស្ស ពលករចំណាកស្រុកខ្មែរជាច្រើននៅក្នុងប្រទេសថៃត្រូវបានគេរាយការណ៍ថាមិនបានដឹងពី របៀបដាក់ពាក្យសុំឯកសារធ្វើដំណើរ ឬថាត្រូវចំណាយអស់ប៉ុន្មាននោះទេ ដែលការណ៍នេះធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យខ្ពស់ក្នុងការធ្វើដំណើរតាមរយៈមធ្យោបាយដែលងាយរងគ្រោះ និងក្រៅផ្លូវការ ហើយរដ្ឋាភិបាលមិនបានចាត់វិធានការគ្រប់គ្រាន់ដើម្បីផ្សព្វផ្សាយព័ត៌មាននោះទេ។ នៅឆ្នាំ ២០២១ គជបជ បានរាយការណ៍ថា ទាហាន និងប៉ូលីសកម្ពុជានៅតាមព្រំដែនថៃបានរារាំងពលករកម្ពុជាចំនួន ៣.៥៨១ នាក់មិនឱ្យចូលប្រទេសថៃ ក្នុងនោះមានស្ត្រី ១.៣២៥ នាក់ និងកុមារ ១៣១ នាក់ ។ ទោះយ៉ាងណាក៏ដោយ គជបជ មិនបានរាយការណ៍ថាតើខ្លួនបានពិនិត្យលើជនចំណាកស្រុកទាំងនោះថាមានករណីជួញដូរ ឬបញ្ជូនពួកគេទៅទទួលយកសេវាការពារនោះទេ។ មន្ត្រីបានផ្តល់អាហារដល់ពលករចំណាកស្រុកកម្ពុជាចំនួន ១.២៧០នាក់ ដែលស្ថិតក្នុងហានិភ័យ ឬត្រូវបានកំណត់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្សនៅក្នុងប្រទេសថៃ និងបានជួយពលករពីរនាក់ដោះស្រាយវិវាទការងារជាមួយនិយោជកបរទេស។ នៅសាធារណរដ្ឋកូរ៉េ មន្ត្រីកម្ពុជាបានចុះពិនិត្យការដ្ឋានដែលមានពលករកម្ពុជាធ្វើការចំនួន ៨៧លើក និងបានដោះស្រាយវិវាទការងារចំនួន ១៣៧ ករណី ខណៈនៅប្រទេសជប៉ុន មន្ត្រីកម្ពុជាបានចុះសួរសុខទុក្ខចំនួន ២៧លើក តាមកន្លែងធ្វើការដែលមានពលករកម្ពុជាច្រើន និងបានជួយដោះស្រាយវិវាទការងារចំនួន ៧៤ ករណី។ រដ្ឋាភិបាលមិនបានរាយការណ៍ថាតើមន្ត្រីបានធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដែរឬទេ ក្នុងចំណោមករណីវិវាទការងារទាំងអស់នោះ។ រដ្ឋាភិបាលបានបន្តអនុវត្តកិច្ចព្រមព្រៀងជ្រើសរើសពលករពីរជាមួយអារ៉ាប៊ីសាអូឌីត កិច្ចព្រមព្រៀងជ្រើសរើសពលករតាមផ្ទះជាមួយហុងកុង និងកិច្ចព្រមព្រៀងសហប្រតិបត្តិការទ្វេភាគីជាមួយឥណ្ឌា។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានបន្តអនុវត្តវិធានការត្រួតពិនិត្យនៅតាមស្ថានកុងស៊ុល ដើម្បីកាត់បន្ថយការជួញដូរផ្លូវភេទ និងការជួញដូរកម្លាំងពលកម្មរបស់ស្ត្រីកម្ពុជាតាមរយៈការបង្ខំ និងអាពាហ៍ពិពាហ៍ក្លែងបន្លំ រួមទាំងការវាយតម្លៃអ្នកដាក់ពាក្យស្នើសុំ ផ្ទៀងផ្ទាត់ជាមួយនឹងប្រវត្តិនៃជនរងគ្រោះដោយការជួញដូរ ដែលបានបង្កើតរួមគ្នាជាមួយប្រទេសចិន ក្នុងឆ្នាំ ២០១៦។ ក្រសួងការបរទេស មិនបានរាយការណ៍អំពីការកំណត់អត្តសញ្ញាណជនរងគ្រោះដែលអាចកើតមានក្នុងអំឡុងពេលត្រួតពិនិត្យទាំងនោះទេ។ រដ្ឋាភិបាលក៏បានបន្តអនុវត្តបទប្បញ្ញត្តិដែលបានអនុម័តក្នុងឆ្នាំ ២០១៨ ដែលតម្រូវឱ្យបុរសបរទេសបង់ថ្លៃប្រសិនបើមានបំណងត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេជាមួយប្តីឬប្រពន្ធកម្ពុជា។ ដោយសារតែបទប្បញ្ញត្តិនេះអនុវត្តចំពោះតែការធ្វើដំណើរតាមផ្លូវអាកាសប៉ុណ្ណោះ អ្នកសង្កេតការណ៍បានរាយការណ៍ពីការកើនឡើងនៃចំនួនស្ត្រីកម្ពុជាដែលធ្វើដំណើរចំណាកស្រុកតាមច្រកផ្លូវគោកដែលមិនមាន

សុវត្ថិភាព ដើម្បីទៅរៀបអាពាហ៍ពិពាហ៍នៅប្រទេសចិន ។ ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០២២ ក្រសួងការបរទេស បានជួយសម្រួលដល់ការវិលត្រឡប់របស់ពលករកម្ពុជាដែលគ្មានឯកសារចំនួន 100,353 នាក់ (ក្នុងនោះមានស្ត្រី 41,178 នាក់ និងកុមារ 12,050 នាក់) ពី ប្រទេសចិន ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ថៃ វៀតណាម និងនីហ្សេរីយ៉ា។

ក្រសួងការងារ បានបន្តអនុវត្តផែនការសកម្មភាពដែលមានគោលបំណងកាត់បន្ថយពលកម្មកុមារ និងចំណងបំណុលការងារក្នុងវិស័យសេវាកម្ម កសិកម្ម រ៉ែ និងថាមពលនៅឆ្នាំ 2025 តាមរយៈការលើកកម្ពស់ការយល់ដឹង សកម្មភាពផ្លូវច្បាប់ និងកិច្ចសហប្រតិបត្តិការជាមួយសង្គមស៊ីវិល ដែលបានផ្តល់មូលនិធិមួយផ្នែកតាមរយៈថវិកាជាតិ។ មន្ត្រីក្រសួងការងារ បានបន្តបដិសេធចំពោះវត្តមាននៃពលកម្មកុមារ រួមទាំងពលកម្មកុមារដោយបង្ខំ និងការបង្ខិតបង្ខំដោយផ្អែកលើបំណុលនៅក្នុងឧស្សាហកម្មឥដ្ឋ។ ក្រសួងការងារ បានធ្វើអធិការកិច្ច ចំនួន ៤០០ ដង ក្នុងឆ្នាំ ២០២២ នៅតាមឡឥដ្ឋ ចំការអំពៅ និងចំការដំឡូងមី ប៉ុន្តែមិនបានរាយការណ៍ពីសញ្ញាណជនរងគ្រោះដោយការជួញដូរ ឬករណីកុមារងាយរងគ្រោះដែលរស់នៅក្នុងបរិវេណឡឥដ្ឋ និងចំការទេ (នៅក្នុងឆ្នាំ ២០២១ មាន៣៥០ករណី)។ អង្គការក្រៅរដ្ឋាភិបាលបាននិយាយថា ប៉ូលីសជាញឹកញាប់មិនបានដឹងថាការរុករកឧក្រិដ្ឋកម្មនៅតាមឡឥដ្ឋ ស្ថិតនៅក្រោមយុត្តាធិការស៊ើបអង្កេតរបស់ពួកគេនោះទេ។ AHTJP យល់ថាការធ្វើអធិការកិច្ចឡឥដ្ឋ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងការងារ ហើយពួកគេស៊ើបអង្កេតតែចំពោះឡឥដ្ឋណាដែលក្រសួងការងារបាន បញ្ជូនករណីនោះទៅពួកគេ តែប៉ុណ្ណោះ។ AHTJP មិនបានរាយការណ៍ពីការបញ្ជូនបែបនេះទេក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ ជារឿយៗអាជ្ញាធរបានធ្វើអធិការកិច្ចដោយមានការជូនដំណឹងជាមុនដល់ម្ចាស់ឡឥដ្ឋ ដោយអនុញ្ញាតឱ្យពួកគេជៀសវាងការផាកពិន័យ ឬលាក់បាំងការរំលោភបំពានដោយយកកុមារចេញពីឡឥដ្ឋមុនពេលមានការធ្វើអធិការកិច្ច។ ក្រសួងទេសចរណ៍ សហការជាមួយ គជបជ បានខិតខំប្រឹងប្រែងកាត់បន្ថយតម្រូវការផ្លូវភេទបែបពាណិជ្ជកម្ម តាមរយៈសិក្ខាសាលាចំនួន ៣ សម្រាប់បុគ្គលិកចំនួន ៩១ នាក់ក្នុងវិស័យទេសចរណ៍ និងមន្ត្រីរដ្ឋាភិបាលស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងឧស្សាហកម្មទេសចរណ៍។ ក្រសួងក៏បន្តផលិតសម្ភារៈសម្រាប់ផ្សព្វផ្សាយជាសាធារណៈ ដែលកំណត់គោលដៅអ្នកប្រើប្រាស់សក្តានុពលនៃការរួមភេទបែបពាណិជ្ជកម្មជាមួយកុមារ។ នៅក្នុងខែកញ្ញា ឆ្នាំ 2022 ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) បានចេញផ្សាយរបាយការណ៍ដែលបានរកឃើញថា ១១ ភាគរយនៃកុមារដែលប្រើប្រាស់អ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជាដែលមានអាយុចន្លោះពី 12-17 ឆ្នាំបានជួបប្រទះការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត (OCSE) ។ CNP បានបន្តរក្សាក្រុមអ្នកឯកទេសប្រឆាំងការជួញដូរ និងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតក្នុងខេត្តនីមួយៗ ដើម្បីស៊ើបអង្កេតករណីពាក់ព័ន្ធនឹង OCSE ។ រដ្ឋាភិបាល ដោយមានកិច្ចសម្របសម្រួលជាមួយអង្គការក្រៅរដ្ឋាភិបាលមួយ ក៏បានធ្វើការងារជាមួយរ៉ឺម៉កកង់បី និងអ្នកបើកតាក់ស៊ីក្នុងស្រុក ដើម្បីទទួលបានរបាយ

ការណ៍នៃការសង្ស័យថាមានការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារនៅតាមសណ្ឋាគារ និងផ្ទះសំណាក់។ ទោះយ៉ាងណាក៏ដោយ ដូចកាលពីឆ្នាំមុនដែរ រដ្ឋាភិបាលជាទូទៅផ្តោតលើការទប់ស្កាត់ជនល្មើសបរទេសនៃទេសចរណ៍ផ្លូវភេទកុមារ ជាជាងកំណត់គោលដៅប្រជាជនក្នុងស្រុក ដែលជាប្រភពសំខាន់នៃតម្រូវការផ្លូវភេទពាណិជ្ជកម្មជាមួយកុមារនៅកម្ពុជា។ រដ្ឋាភិបាលបានបដិសេធមិនឱ្យជនល្មើសផ្លូវភេទបរទេសបួននាក់ចូលមកកម្ពុជានោះឡើយ។

## ប្រវត្តិពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស៖

ដូចដែលបានរាយការណ៍ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ ជនល្មើសជួញដូរមនុស្សបានកេងប្រវ័ញ្ចលើជនរងគ្រោះជាជនជាតិខ្មែរ និងជនរងគ្រោះជាជនបរទេស នៅក្នុងប្រទេសកម្ពុជា ហើយជនល្មើសជួញដូរមនុស្សក៏បានកេងប្រវ័ញ្ចជនរងគ្រោះជនជាតិខ្មែរ ដែលនៅក្រៅប្រទេសផងដែរ។ អង្គការក្រៅរដ្ឋាភិបាល និងសហជីពកម្មករបានរាយការណ៍នៅឆ្នាំ ២០២០ ថា មេខ្យល់ពលករបរទេសបានក្លែងបន្លំជ្រើសរើសជនអន្តោប្រវេសន៍បរទេសរួមមានទាំងមកពីប្រទេសបង់ក្លាដែស ចិន និងនេប៉ាល់ ឱ្យមកធ្វើការនៅក្នុងការដ្ឋានសំណង់ដែលវិនិយោគដោយក្រុមហ៊ុនចិន និងនៅតាមការដ្ឋានសំណង់ផ្សេងទៀតក្នុងប្រទេសកម្ពុជា ដែលអ្នកខ្លះជំពាក់បំណុលក្រុមហ៊ុនជ្រើសរើសពលករ និងធ្លាប់ត្រូវបានគេដកហូតយកលិខិតឆ្លងដែន។ ចាប់តាំងពីឆ្នាំ ២០២១ ប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ថា ជនល្មើសជួញដូរមនុស្សបានបង្ខំឱ្យជនជាតិខ្មែរ និងជនបរទេស ប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតដែលដំណើរការដោយបណ្តាញក្រុមឧក្រិដ្ឋជនក្នុងស្រុកចិន តាមរយៈមជ្ឈមណ្ឌលហៅទូរស័ព្ទដែលមានទីតាំងនៅកម្ពុជា។ ជនល្មើសជួញដូរទាំងនោះប្រើប្រាស់អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីក្លែងបន្លំជ្រើសរើសបុរស ស្ត្រី និងកុមារពីប្រទេសកម្ពុជា និងប្រទេសផ្សេងទៀតក្នុងទ្វីបអាស៊ី អាហ្វ្រិក អឺរ៉ុប អាមេរិកខាងជើង និងអាមេរិកខាងត្បូង កាន់តែច្រើនឡើងៗ ដោយប្រាប់ថាធ្វើការងារបច្ចេកទេសដែលមានប្រាក់ខែខ្ពស់នៅបរទេស ហើយបង្ខំពួកគេឱ្យចូលរួមនៅក្នុងល្បែងអនឡាញ អ៊ិនធឺណិត រូបិយប័ណ្ណគ្រីបតូ និងការបោកប្រាស់តាមទូរស័ព្ទ ជាពិសេសនៅក្នុងបរិវេណទីតាំងពាណិជ្ជកម្មធំៗក្នុងប្រទេសកម្ពុជា។ ជនល្មើសជួញដូរជារឿយៗបានទាក់ទាញជនរងគ្រោះពីបរទេសមកប្រទេសកម្ពុជាដោយប្រើប្រាស់ល្បិចផ្តល់ការងារក្លែងក្លាយ ដែលតាមពិត គឺដាក់ពួកគេឱ្យជាប់ឃុំឃាំងដោយបង្ខំ និងបង្ខំឱ្យប្រព្រឹត្តិបទឧក្រិដ្ឋ។ ជារឿយៗជនរងគ្រោះមកដល់តាមអាកាសយានដ្ឋាន ប៉ុន្តែមានរបាយការណ៍អំពីមេខ្យល់ ដែលដឹកជញ្ជូននាំជនរងគ្រោះមកតាមផ្លូវគោក ឬតាមស

មុទ្រចូលមកកម្ពុជាផងដែរ។ ជនល្មើសជួញដូរដាក់ទណ្ឌកម្មដល់កម្មករទាំងនោះបើបំពេញការងារមិនបានល្អ មិនស្តាប់តាមការបង្គាប់បញ្ជា រួមទាំងមានការរំលោភបំពានលើរាងកាយ ការកាត់ប្រាក់ឈ្នួល និងចំណងបំណុលការងារ ហើយអាចត្រូវបានគេ "លក់បន្ត" ចំពោះអ្នកដែលមិនអាចបំពេញតាមកូតាលក់ ឬមិនអាចសងបំណុលក្នុងការជ្រើសរើសបុគ្គលិកទៅឱ្យបណ្តាញឧក្រិដ្ឋកម្មផ្សេងទៀត - ដោយបង្ខំឱ្យធ្វើការក្នុងគម្រោងការក្លែងបន្លំស្រដៀងគ្នា ការបម្រើតាមផ្ទះ ឬសម្រាប់ការជួញដូរផ្លូវភេទ។ អង្គការមិនមែនរដ្ឋាភិបាលប៉ាន់ស្មានថា កម្មកររហូតដល់១០ម៉ឺននាក់ត្រូវបានគេកេងប្រវ័ញ្ចដោយបង្ខំនៅក្នុងបរិវេណទីតាំងទាំងនោះក្នុងប្រទេសកម្ពុជា។ រហូតមកដល់ខែសីហា ឆ្នាំ ២០២២ ទីតាំងទាំងនោះភាគច្រើនស្ថិតនៅក្នុងតំបន់កំពង់ផែក្រុងព្រះសីហនុ ដែលជាតំបន់សេដ្ឋកិច្ចពិសេសក្រោមកិច្ចព្រមព្រៀងគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ (BRI) រវាងប្រទេសកម្ពុជា និងប្រទេសចិន ប៉ុន្តែមានទីតាំងបន្ថែមរាប់សិបកន្លែងទៀតនៅទូទាំងប្រទេសកម្ពុជា ជាពិសេសនៅតាមតំបន់ជាប់ព្រំដែនជាមួយប្រទេសថៃ និងឡាវ។ ដើម្បីឆ្លើយតបទៅនឹងប្រតិបត្តិការខែសីហា ឆ្នាំ២០២២ របស់រដ្ឋាភិបាលកម្ពុជា ដែលផ្តោតលើ និងស៊ើបអង្កេតក្នុងបរិវេណទីតាំងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិតទាំងនោះ ជនល្មើសជួញដូរបានផ្លាស់ប្តូរពីក្រុងព្រះសីហនុទៅកាន់តំបន់ជនបទកាន់តែច្រើន រួមទាំងទៅកាន់តំបន់សេដ្ឋកិច្ចពិសេសផ្សេងទៀតជាកន្លែងដែលវិនិយោគដោយប្រទេសចិន ជាកន្លែងដែលពួកគេមានការត្រួតពិនិត្យតិចតួចដោយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងជាកន្លែងដែលជនរងគ្រោះមានឱកាសតិចតួចក្នុងការរត់គេចខ្លួន។ មនុស្សពេញវ័យ និងកុមារកម្ពុជាធ្វើចំណាកស្រុកទៅកាន់ប្រទេសផ្សេងទៀតនៅក្នុងតំបន់ និងកាន់តែខ្លាំងឡើងទៅកាន់មជ្ឈិមបូព៌ាដើម្បីធ្វើការងារ។ ជនល្មើសជួញដូរបង្ខំមនុស្សជាច្រើន - ជាញឹកញាប់តាមរយៈការបង្ខិតបង្ខំដោយផ្អែកលើបំណុល - ឱ្យធ្វើការលើទូកនេសាទ ក្នុងវិស័យកសិកម្ម សំណង់ រោងចក្រ និងសេវាកម្មក្នុងស្រុក ឬកេងប្រវ័ញ្ចពួកគេក្នុងគោលបំណងជួញដូរផ្លូវភេទ។ ជនចំណាកស្រុកដែលប្រើប្រាស់បណ្តាញធ្វើចំណាកស្រុកមិនប្រក្រតី ភាគច្រើនតាមរយៈមេខ្យល់ដែលគ្មានអាជ្ញាប័ណ្ណ ហើយមានហានិភ័យខ្ពស់ដោយអំពើជួញដូរមនុស្ស ទោះបីជាអ្នកដែលប្រើប្រាស់ភ្នាក់ងារជ្រើសរើសពលករដែលមានអាជ្ញាប័ណ្ណក៏អាចក្លាយជាជនរងគ្រោះនៃពលកម្មដោយបង្ខំ ឬការជួញដូរផ្លូវភេទដែរ។ ក្រុមហ៊ុនដែលកំពុងដំណើរការក្រោមការឧបត្ថម្ភនៃ "កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស" របស់រដ្ឋាភិបាលជប៉ុនបានកេងប្រវ័ញ្ចជនជាតិខ្មែរតាមរយៈពលកម្មដោយបង្ខំក្នុងផ្នែកកែច្នៃម្ហូបអាហារ ការផលិត វិស័យសំណង់ និងការនេសាទ។ កុមារមកពីគ្រួសារក្រីក្រងាយរងគ្រោះនឹងពលកម្មដោយបង្ខំ ដែលជារឿយៗមានការឃុបឃិតពីសំណាក់សមាជិកគ្រួសាររបស់ពួកគេ ដែលរួមមានទាំងការឱ្យពួកគេទៅបម្រើតាមផ្ទះ និងការសុំទានដោយបង្ខំ ឬឱ្យទៅលក់ដូរតាមដងផ្លូវនៅក្នុងប្រទេសថៃ និងវៀតណាម។ ក្នុងចំណោមប្រជាជនកម្ពុជាពី ១,៥ ទៅ ២ លាននាក់ដែលកំពុងធ្វើការក្នុងប្រទេសថៃមុនពេលមានជំងឺរាតត្បាត ៣០ ទៅ ៤០ ភាគរយនៃពួកគេជាពលករចំណាកស្រុក ដែលគ្មានឯកសារត្រឹមត្រូវ ហើយដែលមានហានិភ័យខ្ពស់ចំពោះអំពើជួញដូរដោយសារតែស្ថានភាពអន្តោ

ប្រវេសន៍របស់ពួកគេ ហើយស្ថានភាពនោះក៏ដូចពលរដ្ឋកម្ពុជាដែលគ្មានឯកសារដែលកំពុងធ្វើការនៅប្រទេសវៀតណាមដែរ។ ជំងឺរាតត្បាតបានប៉ះពាល់ដល់របៀបនៃការធ្វើចំណាកស្រុក និងវិស័យមួយចំនួនក្នុងឆ្នាំ 2020 ដូចជាក្នុងវិស័យសំណង់ ដែលបានធ្វើឱ្យក្រុមងាយរងគ្រោះមួយចំនួនមានហានិភ័យនៃការជួញដូរកាន់តែខ្លាំងជាងឆ្នាំមុន។ ចាប់ពីខែកុម្ភៈ ឆ្នាំ ២០២០ ដល់ ខែកុម្ភៈ ឆ្នាំ ២០២១ ពលករកម្ពុជាជាង ១៥ ម៉ឺននាក់បានវិលត្រឡប់មកកម្ពុជាវិញពីប្រទេសផ្សេងៗ ជាពិសេសប្រទេសថៃ ដោយសារការបិទឧស្សាហកម្មដែលបណ្តាលមកពីជំងឺរាតត្បាត។

ក្រុមជនល្មើសជួញដូរនៅតែបន្តជ្រើសរើសបុរស និងក្មេងប្រុសកម្ពុជាមួយចំនួនធំនៅក្នុងប្រទេសថៃ ដើម្បីធ្វើការលើទូកនេសាទ និងកេងប្រវ័ញ្ចពួកគេតាមរយៈពលកម្មដោយបង្ខំនៅលើនាវាដែលគ្រប់គ្រងដោយប្រទេសថៃ ហើយប្រតិបត្តិការនៅក្នុងដែនទឹកអន្តរជាតិ។ ជនរងគ្រោះកម្ពុជាដែលរត់គេចពីជនល្មើសជួញដូរត្រូវបានកំណត់អត្តសញ្ញាណក្នុងប្រទេសហ្វីជី ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ម៉ូរីស ប៉ាពួញូហ្គីណេ សេណេហ្គាល់ និងអាហ្វ្រិកខាងត្បូង។ បុរសខ្មែរដែលធ្វើការលើកប៉ាល់នេសាទដែលគ្រប់គ្រង និងដំណើរការដោយជនជាតិថៃ រាយការណ៍ពីវិធីសាស្ត្រជ្រើសរើសបុគ្គលិកតាមបែបបោកបញ្ឆោត ការរំលោភបំពានរាងកាយធ្ងន់ធ្ងរ ការផ្តល់ប្រាក់ឈ្នួលទាប ឬការមិនផ្តល់ប្រាក់ឈ្នួល ការរឹតត្បិតសិទ្ធិទទួលបានការថែទាំសុខភាព និងការបង្ខាំងនៅសមុទ្រជាច្រើនឆ្នាំក្នុងមួយលើកៗ ដោយគ្មានការអនុញ្ញាតឱ្យចូលឆ្នេរសមុទ្រ។ ជនល្មើសជួញដូរជ្រើសរើសស្ត្រី និងក្មេងស្រីខ្លះមកពីតំបន់ជនបទ ក្រោមការក្លែងបន្លំដើម្បីធ្វើដំណើរទៅប្រទេសចិន ដើម្បីរៀបការជាមួយបុរសជនជាតិចិន ។ ស្ត្រីទាំងនោះជំពាក់បំណុលមេខ្យល់រាប់ពាន់ដុល្លារ ដែលជាអ្នកសម្របសម្រួលដំណើរការនោះ។ បុរសចិនបានបង្ខំស្ត្រីទាំងនេះខ្លះឱ្យទៅធ្វើការក្នុងរោងចក្រ ឬកេងប្រវ័ញ្ចពួកគេក្នុងការជួញដូរផ្លូវភេទ ដើម្បីសងបំណុលនេះ។ ឪពុកម្តាយខ្លះត្រូវបានគេរាយការណ៍ថាទទួលបានពី 1,500 ទៅ 3,000 ដុល្លារពីមេខ្យល់ដើម្បីបញ្ជូនកូនស្រីរបស់ពួកគេទៅរៀបការនៅចិន។ ស្ត្រីកម្ពុជាដែលបម្រើដោយស្ម័គ្រចិត្តជាអ្នកពពោះជំនួសដោយខុសច្បាប់ឱ្យគ្រួសារចិន ងាយរងគ្រោះដោយការបង្ខាំង និងការបម្រើតាមផ្ទះ។ ជនគ្មានសញ្ជាតិ ដូចជានៅក្នុងសហគមន៍ជនជាតិភាគតិចវៀតណាម មានហានិភ័យខ្ពស់នៃការជួញដូរ ដោយសារកង្វះឯកសារអត្តសញ្ញាណចាំបាច់សម្រាប់ការទទួលបានការងារផ្លូវការ ការអប់រំ ការចុះឈ្មោះអាពាហ៍ពិពាហ៍ ប្រព័ន្ធតុលាការ ឬសិទ្ធិកាន់កាប់ដីធ្លី។

ម្ចាស់សិប្បកម្មឡឥដ្ឋបានធ្វើឱ្យប្រជាជនកម្ពុជាជាង 10,000 នាក់ដែលរស់នៅក្នុងបរិវេណឡឥដ្ឋ រួមទាំងកុមារជិត 4,000 នាក់ ទទួលរងការបង្ខិតបង្ខំឱ្យធ្វើការដោយផ្អែកលើបំណុលច្រើនជំនាន់ ដោយទិញប្រាក់កម្ចីដែលមានស្រាប់របស់ពួកគេ ឬដោយតម្រូវឱ្យពួកគេខ្ចីប្រាក់ជាថ្មី ជាផ្នែកនៃលក្ខខណ្ឌការងារ ឬដើម្បីរ៉ាប់រងថ្លៃព្យាបាលដែលបណ្តាលមកពីគ្រោះថ្នាក់ដែលកើតឡើងក្នុងពេលកំពុងធ្វើការ។ របាយការណ៍របស់អង្គការមិនមែនរ

ដ្ឋាភិបាលក្នុងឆ្នាំ 2016, 2019, និង 2021 បានបញ្ជាក់ពីករណីនៃពលកម្មកុមារ រួមទាំងពលកម្មកុមារដោយបង្ខំនៅក្នុងឡឥដ្ឋ ដោយសារកុមារត្រូវបានបង្ខំឱ្យធ្វើការជាមួយឪពុកម្តាយរបស់ពួកគេតាមរយៈការបង្ខិតបង្ខំដោយផ្អែកលើបំណុល។ បណ្តាញអង្គការមីក្រូហិរញ្ញវត្ថុ និងម្ចាស់បំណុលឯកជន ដ៏ធំធេង ទូលំទូលាយ និងភាគច្រើនមិនមានការគ្រប់គ្រងត្រួតពិនិត្យត្រឹមត្រូវ បានចូលរួមចំណែកក្នុងការរៀបចំនេះដោយការផ្សព្វផ្សាយប្រាក់កម្ចីយ៉ាងសកម្មដល់គ្រួសារនៅក្នុងសហគមន៍ងាយរងគ្រោះ និងភ្ជាប់ទំនាក់ទំនងពួកគេជាមួយសិប្បកម្មឡឥដ្ឋ។ គ្រួសារកសិករនៅជនបទមានហានិភ័យខ្ពស់ចំពោះទម្រង់នៃពលកម្មដោយបង្ខំនេះ ដោយសារបញ្ហាលំបាកផ្នែកសេដ្ឋកិច្ចដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ។ ទឹកភ្លៀងធ្លាក់មិនទៀងទាត់ និងការបាត់បង់ដំណាំជាបន្តបន្ទាប់ជំរុញឱ្យកសិករជាច្រើនខ្ចីប្រាក់មួយចំនួនធំសម្រាប់បង្កើតប្រព័ន្ធធារាសាស្ត្រថ្មី ឬដើម្បីទិញថ្នាំសម្លាប់សត្វល្អិត ហើយម្ចាស់ឡឥដ្ឋតែងតែផ្តល់ប្រាក់កម្ចីទាំងនេះជាមធ្យោបាយរក្សាកម្លាំងពលកម្មរបស់ពួកគេ។ ការអូសបន្លាយរដូវវស្សាក៏ពន្យារពេលដំណើរការសម្ងួតឥដ្ឋ ដោយកាត់បន្ថយប្រាក់ឈ្នួលរបស់កម្មករឡឥដ្ឋទាំងនេះ ហើយបង្ខំឱ្យមនុស្សជាច្រើនជំពាក់បំណុលបន្ថែមទៀតដល់ម្ចាស់ឡឥដ្ឋ។ ដើម្បីរារាំងកម្មករកុំឱ្យរត់គេចពីស្ថានភាពរំលោភបំពាន ម្ចាស់ឡឥដ្ឋមួយចំនួនត្រូវបានរាយការណ៍ថាអនុញ្ញាតឱ្យតែសមាជិកក្រុមគ្រួសារមួយចំនួនប៉ុណ្ណោះដែលអាចឈប់សម្រាកក្នុងថ្ងៃបុណ្យសាធារណៈ ឬដើម្បីទៅព្យាបាលជំងឺនៅពេលណាមួយ។ កម្មករខ្លះរាយការណ៍ពីការបន្តបង្ខាំង និងបង្ខំឱ្យធ្វើការនៅក្នុងឡឥដ្ឋជាយូរបន្ទាប់ពីពួកគេបានសងបំណុលរបស់ពួកគេរួចរាល់។ គ្រួសារមួយចំនួនក៏អាចជួបប្រទះនឹងស្ថានភាពដែលត្រូវគេបង្ខំឱ្យធ្វើការក្នុងដំណើរជីកយកដីឥដ្ឋសម្រាប់យកទៅធ្វើឥដ្ឋ។ ជនល្មើសជួញដូរបានកេងប្រវ័ញ្ចលើកុមារដែលមានអាយុក្រោម 13 ឆ្នាំឱ្យទៅបម្រើតាមផ្ទះ និងនៅក្នុងផ្ទះបនដើម្បីសងបំណុលគ្រួសារដែលកើតឡើងតាមរយៈប្រព័ន្ធនេះ។ សហគមន៍ដែលត្រូវបានផ្លាស់ទីលំនៅដោយប្រតិបត្តិការកាប់ឈើខុសច្បាប់ ផ្គត់ផ្គង់ឈើដល់លើឡឥដ្ឋជាថ្នូរដើម្បីទិញប្រេងឥន្ធនៈ អាចប្រឈមនឹងហានិភ័យខ្ពស់នៃការជួញដូរ រួមទាំងការកាប់ឈើដោយខ្លួនឯង និងកន្លែងផ្សេងទៀតដែលជាលទ្ធផលនៃបញ្ហាលំបាកផ្នែកសេដ្ឋកិច្ច។

ខេត្តទាំង ២៥ របស់ប្រទេសកម្ពុជា គឺជាប្រភពនៃអំពើជួញដូរមនុស្ស។ ការជួញដូរផ្លូវភេទ ភាគច្រើនធ្វើឡើងដោយលាក់កំបាំង។ ស្ត្រី និងកុមារី ជនជាតិខ្មែរ និងជនជាតិដើមភាគតិចវៀតណាម ផ្លាស់ប្តូរទីលំនៅពីតំបន់ជនបទទៅកាន់ទីក្រុង និងតំបន់ទេសចរណ៍ ដែលឧក្រិដ្ឋជនកេងប្រវ័ញ្ចពួកគេដើម្បីជួញដូរផ្លូវភេទនៅក្នុងផ្ទះបន និងជាញឹកញាប់ជាងនេះទៅទៀត កន្លែងរួមភេទដោយសម្ងាត់នៅសួនស្រាបៀរ ហាងម៉ាស្សា ហាងកែសម្ផស្ស ហាងខារ៉ាអូខេ កន្លែងលក់រាយ និង គេហទំព័រមិនមែនបែបពាណិជ្ជកម្ម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការកើនឡើងយ៉ាងឆាប់រហ័ស និងដោយមិនមានការគ្រប់គ្រង នៃកាស៊ីណូ គ្រឹះស្ថានកម្សាន្តដែលគ្រប់គ្រងដោយជនជាតិចិន និងសហគ្រាសពាណិជ្ជកម្មផ្សេងទៀតនៅក្នុងខេត្តព្រះសីហនុ បាននាំឱ្យមានការកើនឡើងនៃការជួញដូរផ្លូវ

ភេទក្នុងស្រុក និងពលកម្មដោយបង្ខំក្នុងចំណោមស្ត្រី និងកុមារីកម្ពុជា ទោះបីជាមានការហាមឃាត់នៅឆ្នាំ 2020 ពីសំណាក់រដ្ឋាភិបាលកម្ពុជាក៏ដោយ។ លើការលេងល្បែងអនឡាញ និងការបិទជាបន្តបន្ទាប់នៃកាស៊ីណូដែលគ្រប់គ្រងដោយជាតិចិន និងគ្រឹះស្ថានកម្សាន្តផ្សេងទៀតបានកាត់បន្ថយការជួញដូរបែបនេះ។ បុរសកម្ពុជាបង្កើតជាប្រភពដ៏ធំបំផុតនៃតម្រូវការកុមារដែលត្រូវបានកេងប្រវ័ញ្ចក្នុងការជួញដូរផ្លូវភេទ។ ទោះជាយ៉ាងណាក៏ដោយ បុរសមកពីកន្លែងផ្សេងទៀតនៅអាស៊ី អូស្ត្រាលី អឺរ៉ុប អាហ្វ្រិកខាងត្បូង និងសហរដ្ឋអាមេរិក ធ្វើដំណើរមកប្រទេសកម្ពុជា ដើម្បីចូលរួមក្នុងវិស័យទេសចរណ៍ផ្លូវភេទលើកុមារ ដោយមានការសម្របសម្រួលកាន់តែខ្លាំងឡើងតាមរយៈការទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។ កុមារនៅតាមទីក្រុងរាប់ពាន់នាក់ដែលត្រូវបានបន្សល់ទុកដោយគ្រួសារដែលធ្វើចំណាកស្រុកទៅក្រៅប្រទេសដើម្បីធ្វើការ ងាយរងគ្រោះនឹងការជួញដូរផ្លូវភេទ និងពលកម្មដោយបង្ខំ។ អត្រាប្រេវ៉ាឡង់នៃការជួញដូរផ្លូវភេទលើកុមារ និងទេសចរណ៍ផ្លូវភេទកុមារត្រូវបានរាយការណ៍ថាបានធ្លាក់ចុះក្នុងឆ្នាំ 2020 ដោយសារការថយចុះនៃការធ្វើដំណើរឆ្លងប្រទេស និងដោយសារតម្រូវការឱ្យមានការដាក់ឱ្យនៅដាច់ដោយឡែកពីគ្នាដោយសារតែជំងឺរាតត្បាត។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីអនុវត្តច្បាប់បានរាយការណ៍ថា ជំងឺរាតត្បាតបានធ្វើឱ្យមានការកើនឡើងឧប្បត្តិហេតុនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិតនៅឆ្នាំ 2020 ហើយឧប្បត្តិហេតុនៅតែបន្តកើនឡើងរហូតដល់ឆ្នាំ 2022។ ស្ត្រី និងកុមារវៀតណាមដែលភាគច្រើនជាជនរងគ្រោះដោយការបង្ខិតបង្ខំដោយសារបំណុល ធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ហើយត្រូវបានកេងប្រវ័ញ្ច ក្នុងការជួញដូរផ្លូវភេទ។ អង្គការមិនមែនរដ្ឋាភិបាលរាយការណ៍ថា ក្រុមឧក្រិដ្ឋជនបានដឹកជនរងគ្រោះវៀតណាមមួយចំនួនឆ្លងកាត់កម្ពុជា មុនពេលពួកគេត្រូវបានគេកេងប្រវ័ញ្ចនៅក្នុងប្រទេសថៃ និងម៉ាឡេស៊ី។ ជនល្មើសជួញដូរនៅកម្ពុជា ភាគច្រើនជាគ្រួសារ ឬសហគមន៍ ឬបណ្តាញតូចៗនៃឈ្មួញកណ្តាលឯករាជ្យ។ មណ្ឌលកុមារកំព្រាកម្ពុជាមួយចំនួនបានទិញកុមារក្នុងស្រុកពីគ្រួសារដែលមានបញ្ហាសេដ្ឋកិច្ច ហើយធ្វើឱ្យពួកគេខ្វះអាហារូបត្ថម្ភ និងរស់នៅក្នុងស្ថានភាពមិនស្អាត នៅក្នុងទីតាំងរបស់ពួកគេ ក្នុងគោលបំណងទាក់ទាញរកប្រាក់ចំណេញពីការបរិច្ចាគសប្បុរសធម៌។ កុមារទាំងនេះមួយចំនួនមានហានិភ័យបន្ថែមទៀតនៃការជួញដូរផ្លូវភេទ និងការបម្រើតាមផ្ទះ ដែលជាលទ្ធផលនៃការត្រួតពិនិត្យរបស់រដ្ឋាភិបាលមិនល្អចំពោះដំណើរការសុំកូន។